ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ស្តង់ដាសាលាគរុកោសល្យគំរូ

នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

២០២៤

# មុខកថា

រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាពក្នុងគោលបំណងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ដើម្បីចូលរួមក្នុងការសម្រេចគោលបំណងខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍផែនការយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ឆ្នាំ២០២៣-២០២៨ ក្នុងនោះការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានអប់រំគ្រូបង្រៀនផ្សារភ្ជាប់ជាមួយកំណែទម្រង់សាលារៀន គឺជាអាទិភាពមួយនៃកំណែទម្រង់វិស័យអប់រំ។

ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ បានកំណត់គោលដៅក្នុងការបញ្ចប់ការបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងអនុវិទ្យាល័យតាមប្រព័ន្ធ ១២+២ និងអនុវត្តការបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងអនុវិទ្យាល័យតាមប្រព័ន្ធ ១២+៤ និងបរិញ្ញាបត្រ+១ ក្នុងគោលបំណងដំឡើងគុណវុឌ្ឍិគ្រូបង្រៀន និងលើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀនឱ្យស្របនឹងនិន្នាការតំបន់ និងសកលលោក។

ការធានាការបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងចីរភាព ដោយផ្តល់ឱ្យគរុសិស្ស គរុនិស្សិតទទួលបាននូវបំណិនវិជ្ជាជីវៈជាគ្រូបង្រៀនពេញលេញ មុននិងក្រោយពេលចេញទៅបម្រើការងារជាគ្រូបង្រៀននៅតាមសាលារៀនគោលដៅ ទាមទារឱ្យមានស្តង់ដាសាលាគរុកោសល្យគំរូ។ ស្តង់ដាសាលាគរុកោសល្យគំរូអភិវឌ្ឍឡើងដើម្បីវាយតម្លៃលើគុណភាពនិងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន និងធានាបាននូវនិរន្តរភាពនៃដំណើរការគ្រឹះស្ថានដែលមានស្តង់ដាចំនួន០៥ (១) លទ្ធផលបណ្តុះបណ្តាល (២) ធនធានបណ្តុះបណ្តាល (៣) កិច្ចសហប្រតិបត្តិការ (៤) អភិបាលកិច្ចល្អ និង (៥) ការស្រាវជ្រាវ និងនវានុវត្តន៍។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ លេខាធិការដ្ឋាននៃគណៈកម្មការអភិវឌ្ឍន៍ធនធានគ្រូបង្រៀន វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ វិទ្យាស្ថានគរុកោសល្យបាត់ដំបង និងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានចូលរួមក្នុងការអភិវឌ្ឍស្តង់ដាសាលាគរុកោសល្យគំរូនេះ។

ក្រសួងសង្ឃឹមថា សាលាគរុកោសល្យទាំងអស់ និងអង្គភាពពាក់ព័ន្ធក្រោមឱវាទចូលរួមអនុវត្តស្តង់ដានេះប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ថ្ងៃព្រហស្បតិ៍ ៨រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


បុព្វកថា ........ 1

មាតិកា ........ 2

១. សេចក្តីផ្តើម ........ 3

២. គោលបំណង ........ 4

៣. គោលដៅ ........ 4

៤. ស្តង់ដាសាលាគរុកោសល្យគំរូ ........ 4

៤.១. ការរៀបចំស្តង់ដា ........ 5
៤.២. សូចនាករនៃស្តង់ដាសាលាគរុកោសល្យគំរូ ........ 5
៤.៣. កម្រិតផ្ទៀងផ្ទាត់សូចនាករ ........ 5
៤.៤. ការផ្ទៀងផ្ទាត់លទ្ធផល ........ 5

៥. តារាងស្តង់ដាសាលាគរុកោសល្យគំរូ ........ 6

៦. គោលការណ៍ណែនាំស្តង់ដាសាលាគរុកោសល្យគំរូ ........ 19

ស្តង់ដាទី១ ៖ លទ្ធផលបណ្តុះបណ្តាល ........ 19

ស្តង់ដាទី២ ៖ ធនធានបណ្តុះបណ្តាល ........ 20

ស្តង់ដាទី៣ ៖ កិច្ចសហប្រតិបត្តិការ ........ 21

ស្តង់ដាទី៤ ៖ អភិបាលកិច្ចល្អ ........ 22

ស្តង់ដាទី៥ ៖ ការស្រាវជ្រាវ និងនវានុវត្តន៍ ........ 23

៧. ការវាយតម្លៃស្តង់ដាសាលាគរុកោសល្យគំរូ ........ 24

៧.១. ឧបករណ៍វាយតម្លៃស្តង់ដាសាលាគរុកោសល្យគំរូ ........ 24
៧.២. របៀបវាយតម្លៃស្តង់ដាសាលាគរុកោសល្យគំរូ ........ 24

៨. បែបបទ និងនីតិវិធីនៃការវាយតម្លៃស្តង់ដាសាលាគរុកោសល្យគំរូ ........ 25

៨.១. គោលការណ៍ទូទៅ និងលក្ខណៈវិនិច្ឆ័យ ........ 25
៨.២. យន្តការ បែបបទ និងនីតិវិធី ........ 25

៩. សេចក្តីសន្និដ្ឋាន ........ 25

ឧបសម្ព័ន្ធ៖ បែបបទនិងនីតិវិធីនៃការវាយតម្លៃសាលាគរុកោសល្យគំរូ ........ 26

## ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៧ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដោយបានកំណត់យកអាទិភាពគន្លឹះចំនួន៥ រួមមាន មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ដើម្បីឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ចនិងសង្គម ព្រម ទាំងតម្រូវការក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចដែលជាគ្រឹះ និងជាមធ្យោបាយដ៏សំខាន់នៃការសម្រេចបាន ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០។ ដូចនេះ ការអភិវឌ្ឍមូលធនមនុស្សត្រូវបានកំណត់យកជាអាទិភាពគន្លឹះក្នុងបញ្ចកោណទី១ រួមមាន (១) ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (២) ការបណ្តុះបណ្តាលជំនាញ បច្ចេកទេស (៣) ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន (៤) ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធ ស្បៀង និង (៥) ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គម ដែលមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។

ឆ្លើយតបនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងយកចិត្តទុកដាក់ លើគុណភាពនៃការបណ្តុះបណ្តាលធនធានមនុស្សដើម្បីអភិវឌ្ឍប្រទេសជាតិ និងឆ្លើយតបទៅនឹងសកលភាវូបនីយកម្ម អប់រំ ទាំងនៅក្នុងតំបន់ និងនៅក្នុងសកលលោក។ ក្នុងន័យនេះ កំណែទម្រង់សាលាគរុកោសល្យត្រូវបានកំណត់ជា អាទិភាព សំដៅផ្តល់ការបណ្តុះបណ្តាល និងអភិវឌ្ឍធនធានគ្រូបង្រៀន ដែលជាអ្នកបន្តវេនកសាងធនធានមនុស្ស សម្រាប់អភិវឌ្ឍប្រទេសជាតិ។

បច្ចុប្បន្ននេះ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនមាន២៤ រួមមាន (១) សាលាមធ្យមសិក្សាគរុកោសល្យ មត្តេយ្យមជ្ឈិម ០១ មានតួនាទីបណ្តុះបណ្តាលគ្រូបង្រៀនមត្តេយ្យសិក្សាតាមប្រព័ន្ធ ១២+២ (២) សាលាគរុកោសល្យ និងវិក្រឹតការ ១៦ មានតួនាទីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+២ (៣) មជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគ ០៤ មានតួនាទីបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+២ (៤) វិទ្យាស្ថាន គរុកោសល្យ ០២ មានតួនាទីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិតាមប្រព័ន្ធ ១២+៤ និងបរិញ្ញាបត្រ+១ និង (៥) វិទ្យាស្ថានជាតិអប់រំ ០១ មានតួនាទីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តមតាមប្រព័ន្ធ បរិញ្ញាបត្រ+២។ កន្លងទៅនេះ ទោះបីជាមានការខ្វះខាតទាំងលើមូលដ្ឋានធនធានមនុស្ស និងធនធានសម្ភារៈក៏ ដោយ ក៏គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនបានបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាព អាស្រ័យដោយ ការខិតខំប្រឹងប្រែងរបស់បុគ្គលិកអប់រំ និងអ្នកពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ដើម្បីបំពេញតម្រូវការរបស់សាលារៀន និងការ ទទួលខុសត្រូវខ្ពស់។ ដោយឡែកស្ថានភាពនៃគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននីមួយៗ នៅពុំទាន់មានការអភិវឌ្ឍ ដូចគ្នានៅឡើយ ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ធនធាន បរិស្ថាន កម្មវិធី ប្រព័ន្ធបណ្តុះបណ្តាល ជាពិសេសគុណភាពនៃ ការបណ្តុះបណ្តាលគ្រូបង្រៀន។ ផ្តើមចេញពីស្ថានភាពនេះ ស្របតាមបរិការណ៍ថ្មី ក្រសួងបានអភិវឌ្ឍស្តង់ដាសាលា គរុកោសល្យគំរូ ដើម្បីឱ្យការបណ្តុះបណ្តាលគ្រូបង្រៀនធានាបាននូវនិរន្តរភាព ប្រសិទ្ធភាព និងគុណភាព។

តើស្តង់ដាសាលាគរុកោសល្យគំរូជាអ្វី? ស្តង់ដាសាលាគរុកោសល្យគំរូ ជាការកំណត់ ឬកម្រិតលក្ខណៈគំរូនៃ សាលាគរុកោសល្យ ក្នុងគោលបំណងអភិវឌ្ឍការបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងចីរភាព ហើយមានលក្ខណៈអាចវាស់វែងបានតាមរយៈសូចនាករ នៃស្តង់ដានីមួយៗ ដែល សាលាគរុកោសល្យត្រូវសម្រេចឱ្យបានដើម្បីក្លាយទៅជាសាលាគរុកោសល្យគំរូ។ ស្តង់ដានេះជាឧបករណ៍បង្ហាញផ្លូវ សម្រាប់អភិវឌ្ឍសាលាគរុកោសល្យលើគ្រប់ផ្នែកទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ធនធានមនុស្ស បច្ចេកទេស សកម្មភាព និងគុណភាពនៃការបណ្តុះបណ្តាល។

សាលាគរុកោសល្យ មានភារកិច្ចសំខាន់ៗចំនួន ០៣ រួមមាន (១) បណ្តុះបណ្តាលគរុសិស្ស គរុនិស្សិតឱ្យក្លាយជាគ្រូបង្រៀនល្អ (២) រឹក្រឹតការគ្រូបង្រៀនដែលកំពុងបម្រើការងារតាមលក្ខខណ្ឌ ឬគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា និង (៣) ពង្រឹងសមត្ថភាពជាលក្ខណៈបុគ្គលនិងគ្រឹះស្ថានតាមរយៈការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការស្រាវជ្រាវ ការអភិវឌ្ឍវិធីសាស្ត្របង្រៀនថ្មី ដើម្បីជួយឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាពខ្ពស់។

ជាមួយគ្នានេះដែរសាលាគរុកោសល្យទាំងអស់ ត្រូវខិតខំប្រែក្លាយគ្រឹះស្ថានរបស់ខ្លួនទៅជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាព គុណភាព និងឧត្តមភាពដែលរួមមាន៖

- បរិយាកាសបៃតង ប្រកបដោយសុវត្ថិភាព គួរជាទីទាក់ទាញ
- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ សម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានសមត្ថភាពសមស្របតាមការរីកចម្រើននៃវិទ្យាសាស្ត្រអប់រំ
- គណៈគ្រប់គ្រង គ្រូឧទ្ទេស បុគ្គលិក មានសមត្ថភាព និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបំពេញការងារល្អតាមតួនាទី ភារកិច្ច និងស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស
- មានរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់
- កសាងធនធានគ្រូបង្រៀនប្រកបដោយគុណសម្បទាពេញលេញឆ្លើយតបនឹងតម្រូវការអប់រំ ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា និងមានសមត្ថភាពប្រកួតប្រជែងក្នុងតំបន់ និងសកលលោក។

## ២. គោលបំណង

ការរៀបចំស្តង់ដាសាលាគរុកោសល្យគំរូ មានគោលបំណងពង្រឹងស្វ័យគ្រប់គ្រងសាលាគរុកោល្យ និងផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយគុណភាព សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងចីរភាព ដោយផ្តល់ឱ្យគរុសិស្ស គរុនិស្សិតទទួលបាននូវបំណិនវិជ្ជាជីវៈជាគ្រូបង្រៀនពេញលេញ មុននិងក្រោយពេលចេញទៅបម្រើការងារជាគ្រូបង្រៀននៅតាមសាលារៀនគោលដៅ។

## ៣. គោលដៅ

ស្តង់ដាសាលាគរុកោសល្យគំរូមានគោលដៅ៖

- ផ្តល់ជាផែនទីបង្ហាញផ្លូវក្នុងការអភិវឌ្ឍសាលាគរុកោសល្យឱ្យមានលក្ខណៈទំនើប និងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបណ្តុះបណ្តាលគរុសិស្ស គរុនិស្សិតប្រកបដោយគុណភាពខ្ពស់
- បង្កើនប្រសិទ្ធភាព និងគុណភាពនៃការបណ្តុះបណ្តាល និងរឹក្រឹតការគ្រូបង្រៀនឱ្យឆ្លើយតបនឹងបរិវត្តកម្មការអប់រំ ដែលដាក់ចេញដោយក្រសួងអប់រំ យុវជន និងកីឡា
- ជាខ្នាតសម្រាប់វាស់វែងពីកម្រិតគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូបង្រៀន និងជានាបាននូវនិរន្តរភាពនៃដំណើរការគ្រឹះស្ថាន។

## ៤. ស្តង់ដាសាលាគរុកោសល្យគំរូ

ឆ្លើយតបនឹងកំណែទម្រង់គ្រូបង្រៀន ស្តង់ដាសាលាគរុកោសល្យគំរូបានកំណត់លក្ខណៈវិនិច្ឆ័យសំខាន់ៗដែលតម្រូវឱ្យសាលាគរុកោសល្យត្រូវតែមាននិងអនុវត្តឱ្យបាន។ ស្តង់ដានេះមានលក្ខណៈវិនិច្ឆ័យសមស្របអាចអនុវត្តបាន

ឆ្លើយតបទាំងកម្រិតជាតិ និងបណ្ដាប្រទេសក្នុងតំបន់។ ស្ដង់ដាសាលាគរុកោសល្យគំរូរួមមាន ស្ដង់ដារង សូចនាករ និងចំណុចផ្ទៀងផ្ទាត់សូចនាករដែលបញ្ជាក់ពីលក្ខណៈ និងសមត្ថភាពរបស់សាលាគរុកោសល្យ។

### ៤.១. ការរៀបចំស្ដង់ដា

ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ស្ដង់ដាសាលាគរុកោសល្យគំរូចំនួន ៥ ដូចខាងក្រោម៖

ស្ដង់ដាទី១ ៖ លទ្ធផលបណ្ដុះបណ្ដាល

ស្ដង់ដាទី២ ៖ ធនធានបណ្ដុះបណ្ដាល

ស្ដង់ដាទី៣ ៖ កិច្ចសហប្រតិបត្តិការ

ស្ដង់ដាទី៤ ៖ អភិបាលកិច្ចល្អ

ស្ដង់ដាទី៥ ៖ ការស្រាវជ្រាវ និងនវានុវត្តន៍

### ៤.២. សូចនាករនៃស្ដង់ដាសាលាគរុកោសល្យគំរូ

ស្ដង់ដានីមួយៗនឹងត្រូវវាស់វែងដោយសូចនាករទៅតាមចំនួនចាំបាច់ជាក់ស្ដែង។ ស្ដង់ដាសាលាគរុកោសល្យគំរូនេះមានសូចនាករសរុបចំនួន៥១ ដែលក្នុងនោះ ស្ដង់ដាទី១ មានស្ដង់ដារងចំនួន០២ និងសូចនាករចំនួន១១ ស្ដង់ដាទី២ មានស្ដង់ដារងចំនួន០៤ និងសូចនាករចំនួន២០ ស្ដង់ដាទី៣ មានស្ដង់ដារងចំនួន០២ និងសូចនាករចំនួន០៩ ស្ដង់ដាទី៤ មានស្ដង់ដារងចំនួន០៣ និងសូចនាករចំនួន០៧ និងស្ដង់ដាទី៥ មានស្ដង់ដារងចំនួន០២ និងសូចនាករចំនួន០៤។

### ៤.៣. កម្រិតផ្ទៀងផ្ទាត់សូចនាករ

សូចនាករនៃស្ដង់ដានីមួយៗអាចនឹងត្រូវកំណត់ការវាស់វែងតាមបែបបរិមាណវិស័យ ឬតាមបែបគុណវិស័យ អាស្រ័យដោយទិដ្ឋភាពជាក់ស្ដែងនៃចរិតលក្ខណៈសូចនាករនីមួយៗដូចមានបង្ហាញនៅក្នុងតារាងលម្អិតស្ដីពី ស្ដង់ដា និងសូចនាករ។

### ៤.៤. ការផ្ទៀងផ្ទាត់លទ្ធផល

លទ្ធផលនៃការវាយតម្លៃនឹងត្រូវធ្វើឡើងដោយផ្អែកលើពិន្ទុសរុប ទទួលបានពីការបូកពិន្ទុនៃសូចនាករនីមួយៗដែលសម្រេចបាន។ ការដាក់ពិន្ទុទៅលើសូចនាករនីមួយៗ ត្រូវផ្អែកលើភស្តុតាងជាក់ស្ដែង។ សូចនាករដែលមានភស្តុតាងច្បាស់លាស់ថាបានសម្រេចនឹងត្រូវផ្ដល់ពិន្ទុពេញចំនួន ៥ពិន្ទុ។ សាលាគរុកោសល្យនឹងត្រូវបានវាយតម្លៃថាមាន ឬមិនទាន់មានលក្ខណៈគំរូ អាស្រ័យលើពិន្ទុសរុបដែលទទួលបាន ធៀបនឹងពិន្ទុសរុបរួមនៃសូចនាករទាំងអស់នៃស្ដង់ដាទាំង៥ ដោយគណនាជាភាគរយដូចខាងក្រោម៖

- សាលាគរុកោសល្យដែលទទួលបានពិន្ទុសរុបចាប់ពី ៩៥% ឡើង នឹងត្រូវចាត់ទុកថាបានបំពេញស្ដង់ដាសាលាគរុកោសល្យគំរូ *មានស្ដង់ដាពេញលេញ*
- សាលាគរុកោសល្យដែលទទួលបានពិន្ទុសរុបចាប់ពី ៨០% ដល់តិចជាង ៩៥% នឹងត្រូវចាត់ទុកថាបានបំពេញស្ដង់ដាសាលាគរុកោសល្យគំរូ *មានស្ដង់ដា*
- សាលាគរុកោសល្យដែលទទួលបានពិន្ទុសរុបចាប់ពី ៦០% ដល់តិចជាង ៨០% នឹងត្រូវចាត់ទុកថាបានបំពេញស្ដង់ដាសាលាគរុកោសល្យគំរូ *មានស្ដង់ដាអប្បបរមា*

## ៥. តារាងស្តង់ដាសាលាគរុកោសល្យគំរូ

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | ការផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| **ស្តង់ដាទី១ ៖ លទ្ធផលបណ្តុះបណ្តាល** | | | | |
| **១.១. គុណសម្បទាគ្រូបង្រៀនដែលបានបញ្ចប់ការបណ្តុះបណ្តាល** | | | | |
| ១.១.១ | ភាពជាគ្រូបង្រៀន | ១. ចំណេះដឹងស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន<br>២. ការប្រតិបត្តិវិជ្ជាជីវៈស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន<br>៣. ការអនុវត្តគន្លងអាជីព<br>៤. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>៥. មានក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | | |
| ១.១.២ | ការទទួលស្គាល់ | ១. ការទទួលស្គាល់ពីនាយកសាលា<br>២. ការទទួលស្គាល់ពីសហការី<br>៣. ការទទួលស្គាល់ពីសិស្ស<br>៤. ការទទួលស្គាល់ពីមាតា បិតាសិស្ស<br>៥. ការទទួលស្គាល់ពីសហគមន៍ | | |
| ១.១.៣ | ការគាំទ្រសាលារៀនដែលកំពុងបម្រើការឱ្យក្លាយជាសាលារៀនគំរូ | ១. ការចែករំលែកចំណេះដឹងទាក់ទងនឹងវិធីសាស្ត្របង្រៀនថ្មី<br>២. ការចែករំលែកចំណេះដឹងទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល<br>៣. ការចែករំលែកចំណេះដឹងទាក់ទងនឹងការស្រាវជ្រាវប្រតិបត្តិ<br>៤. ការគាំទ្រគ្រូបង្រៀនអភិវឌ្ឍនិងអនុវត្តតេស្តស្តង់ដាក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សដោយផ្តោតលើ PISA[1] និង SEA-PLM[2]<br>៥. ការទទួលខុសត្រូវលើតួនាទីនិងបំណែងចែកភារកិច្ច | | |
| **១.២. លទ្ធផលសិក្សារបស់គរុសិស្ស គរុនិស្សិត** | | | | |
| ១.២.១ | លទ្ធផលវាយតម្លៃលើមុខវិជ្ជាសិក្សា | ភាគរយគរុសិស្ស គរុនិស្សិតទទួលបានពិន្ទុចាប់ពី ៧៥-១០០ លើការវាយតម្លៃមុខវិជ្ជាសិក្សា | | |

[1] កម្មវិធីសម្រាប់ការវាយតម្លៃសិស្សអន្តរជាតិ (Programme for International Student Assessment)

[2] តេស្តវាយតម្លៃលទ្ធផលការសិក្សាសិស្សបឋមសិក្សាតំបន់អាស៊ីអាគ្នេយ៍ (Southeast Asia Primary Learning Metrics)

| ល.រ | សូចនាករ | ចំណុចត្រួតពិនិត្យផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្តុតាង | ពិន្ទុ |
| ១.២.២ | លទ្ធផលវាយតម្លៃកម្មសិក្សាគរុកោសល្យ | ភាគរយគរុសិស្ស គរុនិស្សិតទទួលបានពិន្ទុចាប់ពី ៧៥-១០០ លើការវាយតម្លៃកម្មសិក្សាគរុកោសល្យ ឆ្នាំចុងក្រោយនៃកម្មវិធីបណ្តុះបណ្តាល | | |
| ១.២.៣ | លទ្ធផល វាយតម្លៃគម្រោងស្រាវជ្រាវប្រតិបត្តិ | ភាគរយគរុសិស្ស គរុនិស្សិតដែលបានការពារនិងសរសេររបាយកាណ៍ស្រាវជ្រាវប្រតិបត្តិបញ្ចប់ដោយជោគជ័យ | | |
| ១.២.៤ | ការអនុវត្ត PISA /SEA-PLM/តេស្តស្តង់ដាក្នុងអំឡុងពេលកម្មសិក្សាគរុកោសល្យ | ភាគរយគរុសិស្ស គរុនិស្សិតដែលបានអនុវត្ត PISA/ SEA-PLM/តេស្តស្តង់ដាក្នុងអំឡុងពេលកម្មសិក្សាគរុកោសល្យ | | |
| ១.២.៥ | ចំណេះដឹងភាសាបរទេស | ភាគរយគរុសិស្ស គរុនិស្សិតដែលមានចំណេះដឹងភាសាបរទេសកម្រិតមធ្យម ( Intermediate ) | | |
| ១.២.៦ | ចំណេះដឹង ICT | ភាគរយគរុសិស្ស គរុនិស្សិតដែលមានចំណេះដឹង ICT សម្រាប់ការងាររដ្ឋបាល និង ICT ក្នុងការអប់រំ កម្រិតមធ្យម ( Intermediate ) | | |
| ១.២.៧ | សមត្ថភាពគរុសិស្ស គរុនិស្សិតដែលបញ្ចប់ការបណ្តុះបណ្តាលធៀបនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន | ភាគរយគរុសិស្ស គរុនិស្សិតដែលមានសមត្ថភាពឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន តាមរយៈការវាយតម្លៃលើសមត្ថភាពអប់រំគរុសិស្ស គរុនិស្សិត ( Student Teacher Education Competency ) ឆ្នាំចុងក្រោយ | | |
| ១.២.៨ | លទ្ធផលប្រឡងបញ្ចប់ | ភាគរយគរុសិស្ស គរុនិស្សិតប្រឡងបញ្ចប់ជាប់ជាស្ថាពរដែលទទួលបានពិន្ទុចាប់ពី ៧៥-១០០ | | |
| **ស្តង់ដាទី២ ៖ ធនធានបណ្តុះបណ្តាល** | | | | |
| ២.១. ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | | | | |
| ២.១.១ | ហេដ្ឋារចនាសម្ព័ន្ធ | ១. ប្លង់មេ<br>២. អគារសិក្សា<br>៣. បណ្ណាល័យ | | |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | ករម្រិតផ្ទៀតផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | ៤. បន្ទប់ពិសោធន៍<br>៥. អគាររដ្ឋបាល<br>៦. សាលពហុបំណង<br>៧. អន្តេវាសិកដ្ឋានគរុសិស្ស គរុនិស្សិត<br>៨. អន្តេវាសិកដ្ឋានគ្រូឧទ្ទេស<br>៩. រោងជាង-គេហកិច្ច<br>១០. អាហារដ្ឋាន<br>១១. ឃ្លាំងសម្ភារៈ<br>១២. ទីលានកីឡា<br>១៣. ទីលានអត្តពលកម្ម<br>១៤. សួនបំណិនជីវិត<br>១៥. សួនច្បារ<br>១៦. ខ្លោងទ្វារ និងរបង<br>១៧. បណ្តាញប្រព័ន្ធ (ទឹក ភ្លើង ផ្លូវ លូ)<br>១៨. ប្រព័ន្ធសុវត្ថិភាព ប្រព័ន្ធបច្ចេកវិទ្យា ប្រព័ន្ធទំនាក់ទំនង<br>១៩. ចំណតយានជំនិះ<br>២០. ជម្រាលជនមានពិការភាព | | |
| ២.១.២ | បន្ទប់សិក្សា | ១. គ្រឿងសង្ហារឹម<br>២. សម្ភារៈសិក្សា<br>៣. សម្ភារៈបច្ចេកវិទ្យាព័ត៌មានចាំបាច់ សម្រាប់ការបង្រៀននិងរៀន (LCD/ក្តារខៀនឆ្លាតវៃ កុំព្យូទ័រ។ល។)<br>៤. សេវាអ៊ិនធឺណិត<br>៥. ផាសុកភាព (ពន្លឺ ម៉ាស៊ីនត្រជាក់ ខ្យល់អាកាស) | | |
| ២.១.៣ | បន្ទប់គ្រូឧទ្ទេស | ១. បន្ទប់ដាច់ដោយឡែកសម្រាប់ដេប៉ាតឺម៉ង់/មុខវិជ្ជា<br>២. សម្ភារៈបច្ចេកវិទ្យាព័ត៌មានចាំបាច់<br>៣. តុបំពេញការងារសម្រាប់គ្រូឧទ្ទេសម្នាក់ៗ | | |

| ល.រ | សូចនាករ | ចំណុចត្រួតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | តស្កាត | ពិន្ទុ |
| | | ៤. សេវាអ៊ិនធឺណិត<br>៥. កន្លែងសម្រាប់ប្រជុំ<br>៦. ទូរក្សាឯកសារ | | |
| ២.១.៤ | បណ្ណាល័យ | ១. ទីតាំង និងបរិវេណ<br>២. ការរៀបចំបរិវេណ<br>៣. លទ្ធភាពប្រើប្រាស់រូបវន្ត និងឌីជីថល<br>៤. មានទូរនិមិត្ត (e-library)<br>៥. លក្ខខណ្ឌតម្រូវបុគ្គលិកសម្រាប់បណ្ណាល័យ<br>៦. គុណវុឌ្ឍិបណ្ណារក្ស<br>៧. តួនាទីបណ្ណារក្សក្នុងការគាំទ្របណ្ណាល័យសតវត្សរ៍ទី២១<br>៨. ការរៀបចំផែនការ និងការផ្សព្វផ្សាយ<br>៩. សេវាទាក់ទងនឹងសមូហកម្មសៀវភៅ<br>១០. សេវាឌីជីថល<br>១១. កម្មវិធីពិសេសដើម្បីឆ្លើយតបតាមគោលដៅនិងចក្ខុវិស័យរបស់គ្រឹះស្ថាន<br>១២. សេវាអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន<br>១៣. បំណែងចែកភារកិច្ច<br>១៤. ម៉ោងប្រតិបត្តិការ<br>១៥. បទបញ្ជាទាំងឡាយសម្រាប់អ្នកប្រើប្រាស់<br>១៦. ការត្រួតពិនិត្យ/ការគ្រប់គ្រងការប្រើប្រាស់សៀវភៅ និងឌីជីថល | | |
| ២.១.៥ | បន្ទប់ពិសោធន៍ | ១. បន្ទប់ពិសោធន៍ដាច់ដោយឡែកសម្រាប់មុខវិជ្ជានីមួយៗ (គណិតវិទ្យាវិទ្យាសាស្ត្រ និងសិក្សាសង្គម)<br>២. សម្ភារៈពិសោធន៍ចាំបាច់សម្រាប់ការបង្រៀននិងរៀន<br>៣. សេវាអ៊ិនធឺណិតគ្រប់បន្ទប់<br>៤. LCD/ក្តារខៀនឆ្លាតវៃ/ទូរទស្សន៍ឆ្លាតវៃ កុំព្យូទ័រ និងសម្ភារៈបច្ចេកវិទ្យាព័ត៌មានចាំបាច់<br>៥. សៀវភៅណែនាំស្តីពី សុវត្ថិភាពក្នុងបន្ទប់ពិសោធន៍ | | |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| ២.១.៦ | បន្ទប់ ICT | ១. បន្ទប់ ICT ជាច់ដោយឡែក<br>២. កុំព្យូទ័រគ្រប់គ្រាន់សម្រាប់ការបង្រៀននិងរៀន<br>៣. សេវាអ៊ិនធឺណិត<br>៤. LCD/ក្តារខៀនឆ្លាតវៃ/ទូរទស្សន៍ឆ្លាតវៃ កុំព្យូទ័រ និងសម្ភារៈបច្ចេកវិទ្យាព័ត៌មានចាំបាច់<br>៥. សៀវភៅណែនាំស្តីពី ការប្រើប្រាស់បន្ទប់ ICT | | |
| ២.១.៧ | បន្ទប់សុខភាព | ១. សម្ភារៈសុខភាព (ស្តង់ដាកញ្ចប់សម្ភារៈសុខភាព)<br>២. សៀវភៅតាមដានសុខភាពសម្រាប់គរុសិស្ស គរុនិស្សិត<br>៣. ផែនការនិងប្រតិបត្តិការបន្ទប់សុខភាព | | |
| ២.១.៨ | បន្ទប់សិល្បៈប្រពៃណី | ១. សម្ភារៈសិល្បៈប្រពៃណី<br>២. ផែនការនិងការអនុវត្តសកម្មភាពសិល្បៈប្រពៃណី | | |
| ២.១.៩ | សាលាគរុកោល្យបៃតង/មេត្រី | ១. ពុំមានសំរាម<br>២. ពុំមានផ្សែងបារី<br>៣. ពុំមានការប្រើប្រាស់គ្រឿងញៀន<br>៤. ពុំមានគ្រឿងស្រវឹង<br>៥. ពុំមានការបៀតបៀន<br>៦. ពុំមានការរើសអើង<br>៧. ពុំមានការគំរាមកំហែង<br>៨. ពុំមានអំពើហឹង្សា | | |
| ២.១.១០ | ការថែទាំហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ និងបរិស្ថាន | ភាគរយហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ និងបរិស្ថានទទួលបានការថែទាំតាមលក្ខណៈបច្ចេកទេស | | |
| **២.២. ធនធានមនុស្ស** | | | | |
| ២.២.១ | កម្រិតគុណវុឌ្ឍិ | ភាគរយគ្រូឧទ្ទេសមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ | | |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | តស្កុតាង | ពិន្ទុ |
| ២.២.២ | កម្រិតវិជ្ជាជីវៈ | ភាគរយគ្រូឧទ្ទេសឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស | | |
| ២.២.៣ | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ១. ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនជាប្រចាំ<br>២. ការចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ<br>៣. ការរៀបចំផែនការសិក្សាវិជ្ជាជីវៈ<br>៤. ការចូលរួមវគ្គបំប៉ន  សិក្ខាសាលា ឬសន្និសីទ<br>៥. ការដំឡើងគុណវុឌ្ឍិ | | |
| **២.៣. កម្មវិធីបណ្តុះបណ្តាល** | | | | |
| ២.៣.១ | កម្មវិធីនិងឯកសារបណ្តុះបណ្តាល | ១. ក្របខណ្ឌកម្មវិធីអប់រំគ្រូបង្រៀន<br>២. កម្មវិធីបណ្តុះបណ្តាលលម្អិត<br>៣. ឯកសារបង្រៀននិងរៀន<br>៤. កញ្ចប់អំណានថ្នាក់ដំបូងនិងគណិតវិទ្យាថ្នាក់ដំបូង PISA  SEA-PLM ឬ តេស្តស្តង់ដា<br>៥. សម្ភារឧបទេស<br>៦. កិច្ចតែងការបង្រៀន<br>៧. វិធីសាស្ត្របង្រៀន<br>៨. ឯកសារសម្រាប់សិក្សាស្រាវជ្រាវបន្ថែម<br>៩. ការប្រើប្រាស់ ICT និងបច្ចេកវិទ្យាឌីជីថលនៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន | | |
| ២.៣.២ | ផែនការបណ្តុះបណ្តាល | ១. ផែនការបណ្តុះបណ្តាលប្រចាំខែ<br>២. ផែនការបណ្តុះបណ្តាលប្រចាំឆមាស<br>៣. ផែនការបណ្តុះបណ្តាលប្រចាំឆ្នាំ<br>៤. កាលវិភាគបង្រៀនតាមមុខវិជ្ជា<br>៥. តារាងបែងចែកគ្រូឧទ្ទេសបង្រៀន<br>៦. បទប្បញ្ញត្តិបណ្តុះបណ្តាល | | |
| ២.៣.៣ | ការពិនិត្យតាមដានការអនុវត្តកម្មវិធីបណ្តុះបណ្តាល | ១. គណៈកម្មការពិនិត្យតាមដាន<br>២. ផែនការពិនិត្យតាមដានការបង្រៀន<br>៣. ឧបករណ៍ពិនិត្យតាមដានការបង្រៀន<br>៤. អធិការកិច្ចការបង្រៀនរបស់គ្រូឧទ្ទេស<br>៥. របាយការណ៍អធិការកិច្ច | | |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| ២.៣.៤ | កម្មវិធីកម្មសិក្សាគរុកោសល្យ | ១. គណៈកម្មការកម្មសិក្សាគរុកោសល្យ<br>២. សៀវភៅណែនាំកម្មសិក្សាគរុកោសល្យ<br>៣. កាលវិភាគកម្មសិក្សាគរុកោសល្យ<br>៤. ឧបករណ៍វាយតម្លៃដាក់ពិន្ទុផ្អែកលើភស្តុតាង<br>៥. របាយការណ៍វាយតម្លៃកម្មសិក្សាគរុកោសល្យ | | |
| ២.៣.៥ | សកម្មភាពក្រៅកម្មវិធីបណ្តុះបណ្តាល | ១. បាឋកថា (អប់រំសីលធម៌ សុជីវធម៌ ចរិយាធម៌ ។ល។)<br>២. កម្មវិធីផ្លាស់ប្តូរគរុសិស្ស គរុនិស្សិតជាមួយគ្រឹះស្ថានអប់រំក្នុង ឬក្រៅប្រទេស<br>៣. ក្លឹបសិក្សា (សិល្បៈ កីឡា យុវជន ការងារសប្បុរសធម៌ ។ល។)<br>៤. កម្មវិធីវប្បធម៌ ប្រពៃណីជាតិផ្សេងៗ<br>៥. ការធ្វើពលកម្មសម្អាតបរិស្ថានគ្រឹះស្ថាន<br>៦. ទស្សនកិច្ចសិក្សា<br>៧. ភាសាបរទេស<br>៨. ICT | | |
| **២.៤. វិក្រឹតការគ្រូបង្រៀន** | | | | |
| ២.៤.១ | ការទទួលស្គាល់ជាអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ១. ការស្នើសុំការទទួលស្គាល់ជាគ្រឹះស្ថានផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>២. ការទទួលបានការទទួលស្គាល់ជាគ្រឹះស្ថានផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពីការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>៣. វគ្គសិក្សាសម្រាប់ការផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>៤. វគ្គសិក្សាដែលបានទទួលស្គាល់គុណភាពពីការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>៥. សិក្ខាកាមបញ្ចប់វគ្គសិក្សាទទួលបានក្រេឌីតដែលបានកត់ត្រាក្នុងប្រព័ន្ធ HRMIS | | |

| ល.រ | សូចនាករ | ចំណុចត្រួតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្តុតាង | ពិន្ទុ |
| ២.៤.២ | ការជំឡើងគុណវុឌ្ឍិ | ១. ក្របខណ្ឌកម្មវិធីជំឡើងគុណវុឌ្ឍិ<br>២. កម្មវិធីបណ្តុះបណ្តាលលម្អិត<br>៣. ខ្លឹមសារមេរៀន<br>៤. សម្ភារឧបទេស<br>៥. គ្រូឧទ្ទេសមានគុណវុឌ្ឍិស្របតាមស្តង់គ្រឹះស្ថានអប់រំគ្រូបង្រៀន | | |
| **ស្តង់ដាទី៣ ៖ កិច្ចសហប្រតិបត្តិការ** | | | | |
| ៣.១. ការផ្សារភ្ជាប់សាលាគរុកោសល្យនិងសាលាអនុវត្តន៍ | | | | |
| ៣.១.១ | ផែនការចុះគាំទ្រសាលាអនុវត្តន៍ | ១. គណៈកម្មការចុះជួយគាំទ្រសាលាអនុវត្តន៍<br>២. ផែនការចុះជួយគាំទ្រសាលាអនុវត្តន៍<br>៣. បំណែងចែកតួនាទី ភារកិច្ច<br>៤. ការចុះជួយសាលាអនុវត្តន៍តាមផែនការ<br>៥. របាយការណ៍លទ្ធផលស្តីពីការចុះជួយគាំទ្រ | | |
| ៣.១.២ | ការគាំទ្រលើការដឹកនាំនិងគ្រប់គ្រង | ១. ការដឹកនាំធ្វើផែនការអភិវឌ្ឍន៍សាលារៀន<br>២. ការដឹកនាំធ្វើផែនការថវិកា ៣ឆ្នាំ<br>៣. ការដឹកនាំធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំ<br>៤. ឧបករណ៍ពិនិត្យតាមដាន វាយតម្លៃការដឹកនាំនិងគ្រប់គ្រង<br>៥. ការពិនិត្យតាមដាន វាយតម្លៃជាប្រចាំលើការដឹកនាំនិងគ្រប់គ្រង<br>៦. ការផ្តល់ព័ត៌មានត្រឡប់និងតម្រង់ទិសដល់គណៈគ្រប់គ្រងសាលារៀន | | |
| ៣.១.៣ | ការគាំទ្រលើការអនុវត្តកម្មវិធីសិក្សា | ១. គ្រូបង្រៀនទាំងអស់មានក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស<br>២. គ្រូបង្រៀនទាំងអស់មានកម្មវិធីសិក្សាលម្អិត<br>៣. ការគាំទ្រដល់គ្រូបង្រៀនក្នុងការរៀបចំផែនការបង្រៀនតាមមុខវិជ្ជាប្រចាំឆមាសនិងប្រចាំឆ្នាំ | | |

| ល.រ | សូចនាករ | ចំណុចត្រួតពិនិត្យផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | ៤. គ្រូបង្រៀនទាំងអស់មានកាលវិភាគបង្រៀនប្រចាំសប្តាហ៍<br>៥. គ្រូបង្រៀនទាំងអស់មានកិច្ចតែងការបង្រៀនគ្រប់មេរៀន<br>៦. ការគាំទ្រគ្រូបង្រៀនក្នុងការផលិតសម្ភារឧបទេស<br>៧. ការគាំទ្រគ្រូបង្រៀនក្នុងការប្រើប្រាស់សម្ភារឧបទេស<br>៨. ការគាំទ្រគ្រូបង្រៀនក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍<br>៩. ការគាំទ្រគ្រូបង្រៀនក្នុងការប្រើប្រាស់បណ្ណាល័យ | | |
| ៣.១.៤ | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀនសាលាអនុវត្តន៍ | ១. ការសិក្សាពីតម្រូវការ ការអភិវឌ្ឍវិជ្ជាជីវៈ<br>២. ការដឹកនាំគ្រូបង្រៀនរៀបចំផែនការសិក្សាវិជ្ជាជីវៈ<br>៣. ការគាំទ្រគ្រូបង្រៀនក្នុងការស្វែងរកវគ្គសិក្សានានាក្នុង HRCPD<br>៤. ការបំប៉នវិធីសាស្រ្តបង្រៀនថ្មីដល់គ្រូបង្រៀនសាលាអនុវត្តន៍<br>៥. ការផ្តល់ប្រឹក្សាគរុកោសល្យជាប្រចាំដល់គ្រូបង្រៀន<br>៦. ការរៀបចំផែនការការសិក្សាស្រាវជ្រាវមេរៀន<br>៧. គ្រូបង្រៀនចូលរួមការសិក្សាស្រាវជ្រាវមេរៀនជាមួយគ្រូឧទ្ទេសតាមផែនការ<br>៨. ការចុះសង្កេតការបង្រៀនរបស់គ្រូបង្រៀន និងផ្តល់ព័ត៌មានត្រឡប់ | | |
| **៣.២. កិច្ចសហប្រតិបត្តិការជាមួយសហគមន៍ គ្រឹះស្ថានអប់រំ និងដៃគូអភិវឌ្ឍ** | | | | |
| ៣.២.១ | ការចូលរួមកិច្ចការសហគមន៍ | ១. ការចូលរួមគាំទ្រដល់កិច្ចការសង្គមផ្សេងៗដូចជាការងារសប្បុរសធម៌ សកម្មភាពកាកបាទក្រហម<br>២. ការចូលរួមសកម្មភាពវប្បធម៌ប្រពៃណី ការងារបរិស្ថាន ដាំដើមឈើ ការគាំពារសុខភាពសង្គម។ល។ | | |

| ល.រ | សូចនាករ | ចំណុចត្រួតផ្ទៀងផ្ទាត់សូចនាករ | ភស្តុតាងផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | ៣. ការរៀបចំតាំងបង្ហាញពិព័រណ៍ស្នាដៃគ្រូឧទ្ទេស និងគរុសិស្ស គរុនិស្សិតប្រចាំឆ្នាំ<br>៤. ការចូលរួមធ្វើបទបង្ហាញចែករំលែកបទពិសោធដល់សហគមន៍<br>៥. ការចែករំលែកចំណេះដឹងដល់សហគមន៍ | | |
| ៣.២.២ | ការស្វែងរកការគាំទ្រពីសហគមន៍ និងដៃគូអភិវឌ្ឍ | ១. ការផ្សព្វផ្សាយពីផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន<br>២. ការស្វែងរកការគាំទ្រពីសហគមន៍ដើម្បីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រ<br>៣. ការស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍ<br>៤. ការទទួលបានការគាំទ្រពីសហគមន៍<br>៥. ការទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍ | | |
| ៣.២.៣ | កិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានអប់រំក្នុងប្រទេស | ចំនួនគ្រឹះស្ថានអប់រំក្នុងប្រទេសដែលបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការ | | |
| ៣.២.៤ | កិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាក្រៅប្រទេស | ចំនួនគ្រឹះស្ថានអប់រំក្រៅប្រទេសដែលបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការ | | |
| ៣.២.៥ | ការចុះគាំទ្រការធ្វើកំណែទម្រង់សាលារៀនឆ្ពោះទៅការសម្រេចបានជាសាលារៀនគំរូ | ចំនួនសាលារៀនដែលបានចុះគាំទ្រនិងទទួលស្គាល់ជាសាលារៀនគំរូ | | |
| **ស្តង់ដាទី៤ ៖ អភិបាលកិច្ចល្អ** | | | | |
| **៤.១. ការដឹកនាំ និងគ្រប់គ្រង** | | | | |
| ៤.១.១ | ប្រព័ន្ធដឹកនាំនិងគ្រប់គ្រង | ១. រចនាសម្ព័ន្ធគ្រប់គ្រង<br>២. បំណែងចែកតួនាទី ភារកិច្ច | | |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្តុតាង | ពិន្ទុ |
| | | ៣. ក្រុមប្រឹក្សាបច្ចេកទេស (ក្រុមប្រឹក្សាភិបាល/ក្រុមប្រឹក្សាពិគ្រោះយោបល់)<br>៤. ក្រុមប្រឹក្សាអប់រំ/ក្រុមប្រឹក្សាវិទ្យាសាស្ត្រ<br>៥. ក្រុមប្រឹក្សាគរុកោសល្យ<br>៦. មានគណៈវគ្គ/គណៈកម្មការយុវជន | | |
| ៤.១.២ | ផែនការអភិវឌ្ឍន៍គ្រឹះស្ថាន | ១. ផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ<br>២. ផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំ<br>៣. ផែនការប្រតិបត្តិប្រចាំឆ្នាំ<br>៤. របាយការណ៍វឌ្ឍនភាព<br>៥. របាយការណ៍លទ្ធផល (សមិទ្ធកម្ម) សម្រេចបានប្រចាំឆ្នាំ | | |
| ៤.១.៣ | ការគ្រប់គ្រងទិន្នន័យគ្រឹះស្ថាន | ១. ប្រព័ន្ធគ្រប់គ្រងទិន្នន័យសារពើភ័ណ្ឌ ទ្រព្យសម្បត្តិរដ្ឋ<br>២. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ<br>៣. ប្រព័ន្ធគ្រប់គ្រងស្ថិតិបុគ្គលិក(កម្រងប្រវត្តិរូបបុគ្គលិក)<br>៤. ប្រព័ន្ធគ្រប់គ្រងស្ថិតិគរុសិស្ស គរុនិស្សិត (កម្រងប្រវត្តិរូបគរុសិស្ស គរុនិស្សិត) (UMS[3])<br>៥. ប្រព័ន្ធគ្រប់គ្រងការបង្រៀននិងរៀន (LMS[4]) | | |
| ៤.១.៤ | ការវាយតម្លៃការបំពេញការងារបុគ្គលិក | ១. ប្រព័ន្ធវាយតម្លៃបុគ្គលិកផ្អែកលើលទ្ធផល<br>២. កិច្ចព្រមព្រៀងការបំពេញការងារប្រចាំឆ្នាំ<br>៣. ការវាយតម្លៃបុគ្គលិកដោយផ្អែកលើលទ្ធផល<br>៤. ការសិក្សាពីលទ្ធផលនៃការវាយតម្លៃដើម្បីផ្តល់ការលើកទឹកចិត្ត និងកែលម្អ<br>៥. ប្រព័ន្ធលើកទឹកចិត្ត | | |

[3] ប្រព័ន្ធគ្រប់គ្រងស្ថិតិគរុសិស្ស គរុនិស្សិត (University Management System)

[4] ប្រព័ន្ធគ្រប់គ្រងការបង្រៀននិងរៀន (Learning Management System)

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| **៤.២. ការធានាគុណភាពគ្រឹះស្ថាន** | | | | |
| ៤.២.១ | ការធានាគុណភាពផ្ទៃក្នុង | ១. ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង<br>២. គណៈកម្មការវាយតម្លៃផ្ទៃក្នុង<br>៣. វដ្តនៃការវាយតម្លៃច្បាស់លាស់៖ ការរៀបចំផែនការ (Plan) ការអនុវត្តការវាយតម្លៃ (Do) ការវាយតម្លៃ និងវាស់វែងលទ្ធផល (Check) និងការកំណត់ចំណុចដែលត្រូវកែលម្អ (Action)<br>៤. ឧបករណ៍វាយតម្លៃលើគ្រប់ផ្នែក<br>៥. ការរៀបចំស្វ័យវាយតម្លៃតាមដេប៉ាតឺម៉ង់/ការិយាល័យ<br>៦. ការពិនិត្យតាមដាន និងវាយតម្លៃ (កាលវិភាគនៃការវាយតម្លៃការប្រមូលរបាយការណ៍និងទិន្នន័យ និងធ្វើការវិភាគ)<br>៧. ការរៀបចំរបាយការណ៍<br>៨. ការផ្សព្វផ្សាយរបាយការណ៍ជាមួយអ្នកពាក់ព័ន្ធ<br>៩. ការរៀបចំឯកសារពាក់ព័ន្ធសម្រាប់ការវាយតម្លៃផ្ទៃក្រៅ | | |
| ៤.២.២ | ការធានាគុណភាពផ្ទៃក្រៅ | ១. គណៈកម្មការវាយតម្លៃអប់រំ<br>២. ស្វ័យវាយតម្លៃ និងរបាយការណ៍វាយតម្លៃ<br>៣. ការដាក់ពាក្យសុំការវាយតម្លៃពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គទក)<br>៤. ការចុះវាយតម្លៃដល់គ្រឹះស្ថានដោយ គទក<br>៥. ការទទួលស្គាល់គុណភាពអប់រំ (បណ្ដោះអាសន្ន ឬពេញសិទ្ធិ) | | |
| **៤.៣. ការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីបណ្ដុះបណ្ដាល** | | | | |
| ៤.៣.១ | ប្រព័ន្ធពិនិត្យតាមដាន និង | ១. យន្តការពិនិត្យ តាមដាន និងវាយតម្លៃ<br>២. ផែនការពិនិត្យ តាមដាន និងវាយតម្លៃ | | |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | គស្តុតាង | ពិន្ទុ |
| | វាយតម្លៃកម្មវិធីបណ្តុះបណ្តាល | ៣. អនុវត្តការពិនិត្យ តាមដាន និងវាយតម្លៃ<br>៤. របាយការណ៍ពិនិត្យតាមដាន វាយតម្លៃ<br>៥. ផ្សព្វផ្សាយលទ្ធផលពិនិត្យតាមដាន វាយតម្លៃជាមួយអ្នកពាក់ព័ន្ធ | | |
| **ស្តង់ដាទី៥ ៖ ការស្រាវជ្រាវ និងនវានុវត្តន៍** | | | | |
| ៥.១. ការលើកកម្ពស់ការងារស្រាវជ្រាវ និងនវានុវត្តន៍ | | | | |
| ៥.១.១ | ការស្រាវជ្រាវប្រតិបត្តិ | ១. សៀវភៅណែនាំការស្រាវជ្រាវប្រតិបត្តិ<br>២. គណៈកម្មការគាំទ្រ ពិនិត្យ ណែនាំ និងកែលម្អការងារស្រាវជ្រាវ និងការបោះពុម្ព<br>៣. គ្រូឧទ្ទេសយ៉ាងតិច៥០% អាចដឹកនាំគរុសិស្សគរុនិស្សិតធ្វើគម្រោងស្រាវជ្រាវប្រតិបត្តិ<br>៤. គ្រូឧទ្ទេសយ៉ាងតិច៥០% ធ្វើការស្រាវជ្រាវប្រតិបត្តិ<br>៥. ការបង្កើតកិច្ចសហការគម្រោងស្រាវជ្រាវរួមគ្នាជាមួយគ្រឹះស្ថានអប់រំនានា | | |
| ៥.១.២ | ការបោះពុម្ពនិងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ | ១. ព្រឹត្តិបត្រស្រាវជ្រាវផ្ទៃក្នុងត្រូវបានបោះពុម្ពផ្សាយប្រចាំឆមាស ឬប្រចាំឆ្នាំ<br>២. ការរៀបចំសន្និសីទស្រាវជ្រាវប្រចាំឆ្នាំដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវក្នុងចំណោមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន<br>៣. ការចូលរួមធ្វើបទបង្ហាញក្នុងវេទិកា និងសន្និសីទស្រាវជ្រាវនានា<br>៤. ការបោះពុម្ពលទ្ធផលស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវ ក្នុងឬក្រៅប្រទេសយ៉ាងតិច២ | | |

| លេ.រ | សូចនាករ | ចំណុចត្រួតពិនិត្យផ្ទៀងផ្ទាត់សូចនាករ | ភស្តុតាងផ្ទៀងផ្ទាត់លទ្ធផល | |
|---|---|---|---|---|
| | | | ភស្តុតាង | ពិន្ទុ |
| | | ៥. របាយការណ៍ស្រាវជ្រាវប្រតិបត្តិរបស់គរុសិស្ស គរុនិស្សិតយ៉ាងតិច២ ត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ឆ្នាំ<br>៦. របាយការណ៍ស្រាវជ្រាវប្រតិបត្តិរបស់គ្រូឧទ្ទេសយ៉ាងតិច៥ ត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ឆ្នាំ | | |
| ៥.២. ការកសាងឯកសារ/សៀវភៅមេរៀន | | | | |
| ៥.២.១ | ការនិពន្ធចងក្រងសៀវភៅមេរៀន | ចំនួនសៀវភៅមេរៀនសម្រាប់បង្រៀនដែលបាននិពន្ធចងក្រងក្នុងចំណោមគ្រូឧទ្ទេសទៅតាមមុខវិជ្ជានីមួយៗស្របតាមកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ | | |
| ៥.២.២ | ការបោះពុម្ពសៀវភៅមេរៀន | ចំនួនសៀវភៅដែលបានបោះពុម្ពសម្រាប់ទុកក្នុងបណ្ណាល័យ និងប្រើប្រាស់សម្រាប់បង្រៀន និងរៀនប្រចាំឆ្នាំ | | |

## ៦. គោលការណ៍ណែនាំស្តង់ដាសាលាគរុកោសល្យគំរូ

### ស្តង់ដាទី១ ៖ លទ្ធផលបណ្តុះបណ្តាល

ស្តង់ដានេះមានស្តង់ដារងចំនួន០២រួមមាន គុណសម្បទាគ្រូបង្រៀនដែលបានបញ្ចប់ការបណ្តុះបណ្តាល និងលទ្ធផលសិក្សារបស់គរុសិស្ស គរុនិស្សិត។ សាលាគរុកោសល្យគំរូត្រូវតែជាគ្រឹះស្ថានដែលបណ្តុះបណ្តាលគ្រូបង្រៀនមានសមត្ថភាពវិជ្ជាជីវៈនិងការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញការងារ មានក្រមសីលធម៌វិជ្ជាជីវៈ ជាពលរដ្ឋល្អ ស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនដែលជាគំរូសម្រាប់សិស្សានុសិស្ស សហការី និងសហគមន៍។

### ១. គុណសម្បទាគ្រូបង្រៀនដែលបានបញ្ចប់ការបណ្តុះបណ្តាល

គ្រូបង្រៀនដែលបានបញ្ចប់ការបណ្តុះបណ្តាលពីសាលាគរុកោសល្យត្រូវមាន គុណសម្បទាស្របស្របតាមស្តង់ដាវិជ្ជជីវៈគ្រូបង្រៀនពេលបំពេញការងារ និងប្រើប្រាស់គុណសម្បទានេះក្នុងការប្រតិបត្តិវិជ្ជាជីវៈជាគ្រូបង្រៀន។ បន្ថែមលើនេះ ពួកគេត្រូវតែជាគ្រូបង្រៀនដែលមានការទទួលស្គាល់ពីភាគីពាក់ព័ន្ធលើសមត្ថភាពក្នុងការបង្រៀន មានការប្តេជ្ញាចិត្តខ្ពស់ មានទំនាក់ទំនងល្អ មានសីលធម៌ ចរិយាធម៌ និងសុជីវធម៌ល្អ និងបានចូលរួមចំណែកអភិវឌ្ឍសាលារៀនដែលពួកគេបំពេញការងារ។

### ២. លទ្ធផលសិក្សារបស់គរុសិស្ស គរុនិស្សិត

លទ្ធផលសិក្សារបស់គរុសិស្ស គរុនិស្សិតនឹងត្រូវពិនិត្យមើលលើផ្នែកសំខាន់ៗក្នុងកំឡុងពេលសិក្សាដូចជាលទ្ធផលសិក្សាលើមុខវិជ្ជាសិក្សា កម្មសិក្សាគរុកោសល្យ គម្រោងសិក្សា និងការស្រាវជ្រាវ។ សាលាគរុកោសល្យគំរូ

ត្រូវមានគរុសិស្ស គរុនិស្សិតទទួលបានលទ្ធលសិក្សាដែលមានពិន្ទុចាប់ពី ៧៥-១០០ យ៉ាងតិច ៩០%។ បន្ថែមពីនេះ គរុសិស្ស គរុនិស្សិតដែលបានបញ្ចប់ការសិក្សាត្រូវបំពេញនូវសមត្ថភាពអប់រំគរុសិស្ស គរុនិស្សិត (Student Teacher Education Competency) មានសមត្ថភាពក្នុងការអនុវត្តវិធីសាស្ត្របង្រៀនដើម្បីបណ្តុះបំណិនសតវត្សរ៍ទី២១ របស់សិស្ស និងជួយគាំទ្រការអនុវត្តកំណែទម្រង់សាលារៀនឆ្ពោះទៅសម្រេចបានស្តង់ដាសាលារៀនគំរូ។

### ស្តង់ដាទី២ ៖ ធនធានបណ្តុះបណ្តាល

ស្តង់ដានេះមានស្តង់ដារងចំនួន ០៤ រួមមាន ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ធនធានមនុស្ស កម្មវិធីបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន។ ធនធានបណ្តុះបណ្តាលជាកត្តាគន្លឹះក្នុងការជំរុញដល់ការបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានគុណភាពខ្ពស់ ដែលសាលាគរុកោសល្យត្រូវតែយកចិត្តទុកដាក់កសាង កៀរគរធនធាន អភិវឌ្ឍ និងថែរក្សាឱ្យបានល្អ។

#### ១. ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

សាលាគរុកោសល្យគំរូត្រូវតែមានហេដ្ឋរចនាសម្ព័ន្ធរូបវន្តស្អាត មានរបៀបរៀបរយល្អ ប្រកបដោយផាសុកភាព និងសុវត្ថិភាពខ្ពស់សម្រាប់គរុសិស្ស គរុនិស្សិតទទួលការបណ្តុះបណ្តាល ព្រមទាំងបុគ្គលិកធ្វើការប្រកបដោយមេត្រីភាព។ សាលាគរុកោសល្យគំរូ ត្រូវរៀបចំការគ្រប់គ្រង និងនិរន្តរភាពនៃការប្រើប្រាស់អាគាររដ្ឋបាល អាគារសិក្សា សាលពហុបំណង រួមទាំងបណ្ណាល័យ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់សិល្បៈ ទីលានកីឡា សម្ភារៈបរិក្ខារ និងធនធានដទៃចាំបាច់ផ្សេងទៀត បម្រើដល់សេវាបណ្តុះបណ្តាលគ្រូបង្រៀន និងជានាការផ្សារភ្ជាប់ពីទ្រឹស្តីទៅការអនុវត្តជាក់ស្តែង។

#### ២. ធនធានមនុស្ស

សាលាគរុកោសល្យគំរូ ត្រូវមានធនធានមនុស្ស ដែលសំដៅដល់ធនធានគ្រូឧទ្ទេស ប្រកបដោយគុណសម្បទាពេញលេញដែលមានកម្រិតគុណវុឌ្ឍិខ្ពស់ជាងកម្រិតត្រូវបណ្តុះបណ្តាលមួយកម្រិតយ៉ាងតិច៥០% មានសមត្ថភាពវិជ្ជាជីវៈឆ្លើយតបស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស មានក្រមសីលធម៌ល្អ និងមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការបំពេញការងារសម្រាប់គរុសិស្ស គរុនិស្សិតយកជាគំរូ។ ជាមួយគ្នានេះដែរ សាលាគរុកោសល្យគំរូត្រូវមានយុទ្ធសាស្ត្រក្នុងការកៀរគរ និងរក្សាធនធានគ្រូឧទ្ទេសដែលមានសមត្ថភាពតាមរយៈការធ្វើសុខដុមនីយកម្មការងារ និងផ្តល់ការលើកទឹកចិត្ត និងឱកាសអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំទាំងនៅកម្រិតគ្រឹះស្ថាន កម្រិតជាតិ និងអន្តរជាតិ។ សាលាគរុកោសល្យគំរូត្រូវមានប្រព័ន្ធវាយតម្លៃការបំពេញការងាររបស់បុគ្គលិកឱ្យបានច្បាស់លាស់ តម្លាភាព និងយុត្តិធម៌ ធានាបាននូវការផ្តល់ការលើកទឹកចិត្ត និងការបង្កើនឋានៈវិជ្ជាជីវៈ ឬតួនាទីដល់អ្នកដែលមានសមត្ថភាពពិតប្រាកដ សំដៅធានាក្នុងការរក្សាបាននូវធនធានល្អ ឈានទៅសម្រេចបានលទ្ធផលបណ្តុះបណ្តាលគរុសិស្ស គរុនិស្សិតប្រកបដោយគុណភាពខ្ពស់។

#### ៣. កម្មវិធីបណ្តុះបណ្តាល

ការផ្គត់ផ្គង់គ្រូបង្រៀនប្រកបដោយគុណសម្បទាខ្ពស់ អាស្រ័យលើការអនុវត្តកម្មវិធីបណ្តុះបណ្តាលប្រកបដោយគុណភាពទាំងនៅក្នុងថ្នាក់រៀននិងក្រៅថ្នាក់រៀន ការវាយតម្លៃការសិក្សារបស់សិស្ស (តេស្តស្តង់ដា PISA និង SEA-PLM)

រួមទាំងការចុះអនុវត្តការបង្រៀន (កម្មសិក្សាគរុកោសល្យ) នៅតាមសាលាអនុវត្តន៍ និងសាលាសហការផងដែរ ដើម្បីដកបទពិសោធក្នុងការដោះស្រាយបញ្ហាជាក់ស្តែងជាមួយសិស្សនៅក្នុងថ្នាក់រៀន។ សាលាគរុកោសល្យគំរូ ត្រូវអនុវត្តការបង្រៀន និងរៀនដោយប្រើប្រាស់ វិធីសាស្ត្របង្រៀនទំនើប ទាន់សម័យ ការរៀនតាមបែបសកម្មទាំងក្នុង និងក្រៅថ្នាក់ ស្របតាមបរិបទសង្គមឌីជីថល ដែលផ្តល់ឱកាសឱ្យគរុសិស្ស គរុនិស្សិតទទួលបាននូវបំណិនសតវត្សរ៍ទី២១ រួមមាន បំណិនគិតពិចារណាបែបស៊ីជម្រៅ បំណិនសហការ បំណិនបង្កើតថ្មី បំណិនទំនាក់ទំនង តាមរយៈការសិក្សាគម្រោង សិក្សាជាក្រុម ការចែករំលែក ស្វ័យសិក្សា ជំនាញស្រាវជ្រាវ។ល។ បន្ថែមពីអ្វីដែលមាននៅក្នុង កម្មវិធីបណ្តុះបណ្តាល សាលាគរុកោសល្យគំរូត្រូវរៀបចំឱ្យមានផងដែរនូវសកម្មភាពក្រៅកម្មវិធីបណ្តុះបណ្តាលដូចជា ក្លឹបសិក្សានានា សកម្មភាពសង្គមវប្បធម៌ សកម្មភាពបរិស្ថាន សកម្មភាពសប្បុរសធម៌ កម្មវិធីបាឋកថា ទស្សនកិច្ចសិក្សា ។ល។

### ៤. វិក្រឹតការគ្រូបង្រៀន

ភារកិច្ចស្នូលរបស់សាលាគរុកោសល្យរួមមាន ការងារបណ្តុះបណ្តាលគ្រូបង្រៀនដំបូង និងការងារវិក្រឹតការគ្រូបង្រៀនដែលកំពុងបំពេញការងារនៅសាលារៀន។ល។ សាលាគរុកោសល្យគំរូ ត្រូវមានការទទួលស្គាល់ជាគ្រឹះស្ថានផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំជូនដល់គ្រូបង្រៀន ដូច្នេះសាលាគរុកោសល្យគំរូត្រូវមានផែនការវិក្រឹតការច្បាស់លាស់ រួមជាមួយនឹងកម្មវិធីសិក្សាលម្អិត និងឯកសារមេរៀនសម្រាប់ធ្វើវិក្រឹតការ ព្រមទាំងផ្តល់នូវកម្មវិធីវិក្រឹតការប្រកបដោយគុណភាពខ្ពស់ដល់គ្រូបង្រៀន។

## ស្តង់ដារទី៣ ៖ កិច្ចសហប្រតិបត្តិការ

សាលាអនុវត្តន៍ជាដៃគូចាំបាច់របស់សាលាគរុកោសល្យ ដើម្បីអនុវត្តកម្មវិធីបណ្តុះបណ្តាលប្រកបដោយប្រសិទ្ធភាព និងគុណភាព ដោយផ្តល់ឱកាសឱ្យគរុសិស្ស គរុនិស្សិតបានផ្សារភ្ជាប់ទ្រឹស្តី និងការអនុវត្ត ក្នុងអំឡុងពេលបណ្តុះបណ្តាល។ សាលាគរុកោសល្យទាំងអស់មានភារកិច្ចក្នុងការដឹកនាំ និងគាំទ្រសាលាអនុវត្តន៍របស់ខ្លួនឱ្យក្លាយជាសាលារៀនគំរូ ដោយត្រូវមានផែនការចុះជួយគាំទ្រលើការងារដឹកនាំនិងគ្រប់គ្រង ការអនុវត្តកម្មវិធីសិក្សា និងផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅនឹងកន្លែងដល់គណៈគ្រប់គ្រងនិងគ្រូបង្រៀនទាំងអស់។ ជាមួយគ្នានេះ សាលាគរុកោសល្យត្រូវបង្កើតដៃគូ សហការផ្សេងទៀត ដូចជាគ្រឹះស្ថានអប់រំពាក់ព័ន្ធនានាទាំងវិស័យឯកជន និងវិស័យរដ្ឋ រួមជាមួយដៃគូអភិវឌ្ឍ និងសហគមន៍ផងដែរ ក្នុងគោលដៅទទួលបានការគាំទ្រនានាដើម្បីបន្តអភិវឌ្ឍសាលាគរុកោសល្យទាំងលើផ្នែករឹង និងផ្នែកទន់ ធានាដល់ការលើកកម្ពស់ការបណ្តុះបណ្តាល និងវិក្រឹតការកាន់តែប្រសើរឡើង។ ស្តង់ដានេះ មានស្តង់ដារងចំនួន ០២ រួមមាន ការផ្សារភ្ជាប់សាលាគរុកោសល្យនិងសាលាអនុវត្តន៍ និងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ គ្រឹះស្ថានអប់រំ និងដៃគូអភិវឌ្ឍ។

### ១. ការផ្សារភ្ជាប់សាលាគរុកោសល្យនិងសាលាអនុវត្តន៍

សាលាគរុកោសល្យគំរូ ត្រូវប្រាស្រ័យទាក់ទងជិតស្និទជាមួយសាលាអនុវត្តន៍ដើម្បីឈ្វេងយល់គ្នាទៅវិញទៅមក ក្នុងគោលបំណងលើកកម្ពស់ការបណ្តុះបណ្តាលគ្រូបង្រៀនឱ្យមានប្រសិទ្ធភាពខ្ពស់។ ក្នុងន័យនេះ សាលាគរុកោសល្យត្រូវសហការជាមួយសាលាអនុវត្តន៍ដើម្បីផ្តល់ឱកាសឱ្យគរុសិស្ស គរុនិស្សិតបានផ្សារភ្ជាប់ទ្រឹស្តីទីនឹងការអនុវត្តជាក់ស្តែង តាមរយៈការចុះសង្កេតលើការងារដឹកនាំគ្រប់គ្រង ការបង្រៀន និងការរៀន ព្រមទាំងអនុវត្តការបង្រៀនផ្ទាល់ជាមួយសិស្សនៅក្នុងថ្នាក់រៀនផងដែរ ដោយមានការចូលរួមណែនាំ ពិនិត្យ ផ្តល់ព័ត៌មានត្រឡប់កែលម្អជាប្រចាំពីសំណាក់

គ្រូឧទ្ទេសសាលាគរុកោសល្យ និងគ្រូបង្រៀនឈរថ្នាក់នៅសាលាអនុវត្តន៍។ សាលាគរុកោសល្យគំរូ ត្រូវធ្វើយ៉ាងណាជួយគាំទ្រដល់សាលាអនុវត្តន៍ឱ្យក្លាយជាសាលារៀនគំរូ ដែលផ្តល់ការសិក្សាប្រកបដោយគុណភាព និងសិស្សទទួលបានលទ្ធផលសិក្សាល្អ។ សាលាគរុកោសល្យគំរូត្រូវមានផែនការច្បាស់លាស់ ដើម្បីធ្វើការគាំទ្រដល់សាលាអនុវត្តន៍ជាពិសេសលើការពង្រឹងការងារគ្រប់គ្រងរបស់គណៈនាយក និងសមត្ថភាពគ្រូបង្រៀន តាមរយៈការបំប៉នបន្ថែមលើវិធីសាស្ត្របង្រៀនថ្មីៗ ការបំប៉នលើខ្លឹមសារមេរៀន ការចុះពិនិត្យកែលម្អការបង្រៀន និងការគាំទ្រការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនជាដើម។

### ២. កិច្ចសហប្រតិបត្តិការជាមួយសហគមន៍ គ្រឹះស្ថានអប់រំ និងដៃគូអភិវឌ្ឍ

ក្នុងគោលបំណងអភិវឌ្ឍគុណភាពបណ្តុះបណ្តាលប្រកបដោយនិរន្តរភាព និងពង្រីកខ្លួនឱ្យមានការទទួលស្គាល់កាន់តែទូលំទូលាយទាំងនៅក្នុងកម្រិតជាតិ និងកម្រិតតំបន់/អន្តរជាតិ សាលាគរុកោសល្យគំរូ ត្រូវបង្កើតឱ្យមានការចូលរួមការងារជាមួយសហគមន៍។ កិច្ចការទាំងនោះអាចមានដូចជា ការផ្សព្វផ្សាយ និងចែករំលែកបទពិសោធល្អៗក្នុងសន្និសីទ ឬវេទិកាផ្សេងៗ កម្មវិធីសប្បុរសធម៌ កិច្ចការសង្គមនានា។ សាលាគរុកោសល្យគំរូ ត្រូវចុះគាំទ្រការធ្វើកំណែទម្រង់សាលារៀនឆ្ពោះទៅការសម្រេចបានជាសាលារៀនគំរូ និងស្វែងរកការគាំទ្រពីសហគមន៍ និងដៃគូអភិវឌ្ឍ មានកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានអប់រំពាក់ព័ន្ធនានាទាំងក្នុងនិងក្រៅប្រទេសដើម្បីផ្លាស់ប្តូរបទពិសោធ និងចំណេះដឹងជាដើម។

## ស្តង់ដារទី៤ ៖ អភិបាលកិច្ចល្អ

អភិបាលកិច្ចជាស្តង់ដារដ៏មានសារៈសំខាន់ ក្នុងការវាស់វែង និងវាយតម្លៃសាលាគរុកោសល្យ ព្រោះវាជាមូលដ្ឋានគ្រឹះនាំទៅសម្រេចស្តង់ដារផ្សេងៗទៀត។ សាលាគរុកោសល្យគំរូ ត្រូវមានរបៀបរបបនៃការដឹកនាំ គ្រប់គ្រងដែលជួយគាំទ្រ សម្របសម្រួល តម្រង់ទិសគ្រប់ផ្នែក ដើម្បីធានាថាដំណើរការបណ្តុះបណ្តាលគ្រូបង្រៀនប្រព្រឹត្តទៅប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ក្នុងគោលបំណងផលិតគ្រូបង្រៀនប្រកបដោយគុណសម្បទាពេញលេញ និងមានក្រមសីលធម៌វិជ្ជាជីវៈខ្ពស់ សម្រាប់បំពេញតម្រូវការនៅតាមសាលារៀន និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សបានកាន់តែប្រសើរ។ ស្តង់ដារនេះ មានស្តង់ដាររងចំនួន ០៣ រួមមាន ការដឹកនាំនិងគ្រប់គ្រង ការធានាគុណភាពគ្រឹះស្ថាន និងការពិនិត្យតាមដាននិងវាយតម្លៃកម្មវិធីបណ្តុះបណ្តាល។

### ១. ការដឹកនាំ និងគ្រប់គ្រង

សាលាគរុកោសល្យគំរូត្រូវមានប្រព័ន្ធដឹកនាំ និងគ្រប់គ្រងប្រកបដោយថាមពល ប្រសិទ្ធភាព សាមគ្គីភាពផ្ទៃក្នុង សុខដុមនីយកម្មការងារ ស្វ័យភាព និងការទទួលខុសត្រូវខ្ពស់ ដែលអាចប្រមូលផ្តុំធនធាននានារួមគ្នាជាចលករជំរុញផលិតផល។ ក្នុងន័យនេះ សាលាគរុកោសល្យគំរូ ត្រូវរៀបចំឱ្យមាននូវរចនាសម្ព័ន្ធគ្រប់គ្រងច្បាស់លាស់ កំណត់តួនាទីភារកិច្ចទទួលខុសត្រូវតាមផ្នែក ឬជំនាញជាក់លាក់ និងបង្កើតឱ្យមានក្រុមការងារគាំទ្រផ្សេងៗទៀតតាមការចាំបាច់របស់គ្រឹះស្ថាន។ ជាមួយគ្នានេះ សាលាគរុកោសល្យត្រូវមានផែនការ និងយន្តការគ្រប់គ្រងច្បាស់លាស់ រួមទាំងការគ្រប់គ្រងទិន្នន័យផងដែរ។

### ២. ការធានាគុណភាពគ្រឹះស្ថាន

ការធានាគុណភាពគ្រឹះស្ថានជាកិច្ចការចម្បងរបស់គ្រឹះស្ថានដែលរួមមាន ការធានាគុណភាពផ្ទៃក្នុងដែលតម្រូវឱ្យមានការិយាល័យធានាគុណភាពផ្ទៃក្នុងនិងគណៈកម្មការឯករាជ្យ និងការធានាគុណភាពផ្ទៃក្រៅដែលតម្រូវឱ្យសាលាគរុកោសល្យបំពេញនូវស្តង់ដាទាំង០៩ របស់គ្រឹះស្ថានឧត្តមសិក្សា មុននឹងរៀបចំពាក្យស្នើសុំការវាយតម្លៃទៅគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

### ៣. ការពិនិត្យ តាមដាន និងវាយតម្លៃកម្មវិធីបណ្តុះបណ្តាល

ដើម្បីធានាបាននូវគុណភាព និងវឌ្ឍនភាពប្រកបដោយនិរន្តរភាព ទាមទារឱ្យសាលាគរុកោសល្យធ្វើការវាយតម្លៃ ផ្តុះបញ្ចាំងលើការអនុវត្តកម្មវិធីបណ្តុះបណ្តាលជាប្រចាំ។ សាលាគរុកោសល្យគំរូ ត្រូវរៀបចំឱ្យមានប្រព័ន្ធពិនិត្យ តាមដាន និងវាយតម្លៃឱ្យបានច្បាស់លាស់ ក្នុងគោលដៅធានាឱ្យបាននូវការអប់រំគ្រូបង្រៀនប្រកបដោយគុណភាពខ្ពស់ ទាំងដំណើរការ និងផលសម្រេច។ ការពិនិត្យតាមដាន និងវាយតម្លៃត្រូវធ្វើឡើងដោយពិនិត្យមើលទាំងលើនិយតភាព ប្រសិទ្ធភាព និងគុណភាពនៃការអនុវត្ត។ លទ្ធផលនៃការពិនិត្យតាមដានត្រូវធ្វើឡើងដោយក្រុមការងារទទួលបន្ទុក ទៅតាមផែនការ នីតិវិធីច្បាស់លាស់ ប្រកបដោយការជឿជាក់ មានលក្ខណៈវិទ្យាសាស្ត្រ ហើយលទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃ ត្រូវធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយក្នុងចំណោមបុគ្គលិក ដើម្បីជាមូលដ្ឋានក្នុងការកែលម្អ ឱ្យកាន់តែប្រសើរឡើងជាងមុន។

## ស្តង់ដាទី៥ ៖ ការស្រាវជ្រាវ និងនវានុវត្តន៍

ឆ្លើយតបនឹងបរិបទនៃការរីកចម្រើនឥតឈប់ឈរនៃសង្គមសេដ្ឋកិច្ចឌីជីថល ទាមទារឱ្យវិស័យអប់រំមានការវិវត្តផ្លាស់ប្តូរពីរបៀបបង្រៀន និងរៀនឱ្យទាន់សម័យកាលផងដែរ។ ក្នុងន័យនេះ សាលាគរុកោសល្យគំរូ មិនត្រឹមតែជាគ្រឹះស្ថានការបណ្តុះបណ្តាលផ្គត់ផ្គង់គ្រូបង្រៀនតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែជាគ្រឹះស្ថានស្រាវជ្រាវផងដែរដើម្បីធានាបាននូវបច្ចុប្បន្នភាព និងនវានុវត្តន៍ថ្មីៗនៃកម្មវិធីសិក្សា ខ្លឹមសារមេរៀន និងវិធីសាស្ត្របង្រៀន។ ជាមួយគ្នានេះដែរ សាលាគរុកោសល្យគំរូត្រូវមានកម្មវិធីបណ្តុះបណ្តាលចំណេះដឹងមូលដ្ឋានស្រាវជ្រាវដល់គរុសិស្ស គរុនិស្សិត ដែលជាអនាគតគ្រូបង្រៀន ដើម្បីឱ្យមានសមត្ថភាពអភិវឌ្ឍបាននូវវិធីសាស្ត្របង្រៀនថ្មី ជួយសិស្សសិក្សាប្រកបដោយប្រសិទ្ធភាពខ្ពស់ ឆ្លើយតបទៅនឹងការវិវត្ត និងតម្រូវការរបស់សង្គមជាតិ។ ស្តង់ដានេះ មានស្តង់ដារងចំនួន ០២ រួមមាន ការលើកកម្ពស់ការងារស្រាវជ្រាវនិងនវានុវត្តន៍ និងការកសាងឯកសារ/សៀវភៅមេរៀន។

### ១. ការលើកកម្ពស់ការងារស្រាវជ្រាវ និងនវានុវត្តន៍

សាលាគរុកោសល្យគំរូ ត្រូវមានយន្តការច្បាស់លាស់ក្នុងការជំរុញ លើកទឹកចិត្តដល់គ្រូឧទ្ទេស និងគរុសិស្ស គរុនិស្សិតធ្វើការសិក្សាស្រាវជ្រាវឱ្យបានផុលផុស និងអភិវឌ្ឍបាននូវវិធីសាស្ត្របង្រៀនថ្មីៗដើម្បីដោះស្រាយបញ្ហាសិក្សារបស់សិស្សទាំងនៅក្នុង និងក្រៅថ្នាក់រៀន សំដៅលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សឱ្យកាន់តែប្រសើរឡើង។ ជាមួយគ្នានេះដែរ សាលាគរុកោសល្យត្រូវបង្កើតឱកាសឱ្យមានកិច្ចសហការស្រាវជ្រាវរួមគ្នាផងដែរជាមួយគ្រឹះស្ថានសិក្សានានា ទាំងក្នុង និងក្រៅប្រទេស។ លើសពីនេះទៅទៀត សាលាគរុកោសល្យត្រូវជំរុញការបោះពុម្ព ផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវដែលទទួលបានទៅដល់សហគមន៍សិក្សាវិជ្ជាជីវៈ ចែករំលែកឧត្តមានុវត្តន៍ដល់គ្រូបង្រៀនដទៃតាមរយៈការបង្កើតឱ្យមានព្រឹត្តបត្រ ឬទស្សនាវដ្ដីស្រាវជ្រាវប្រចាំគ្រឹះស្ថានរបស់ខ្លួន និងផ្តល់ឱកាសដល់គ្រូឧទ្ទេស និងគរុសិស្ស គរុនិស្សិតចូលរួមធ្វើបទបង្ហាញស្នាដៃនៅក្នុងសន្និសីទនានា ជាតិ និងអន្តរជាតិផងដែរ។

### ២. ការកសាងឯកសារ/សៀវភៅមេរៀន

សាលាគរុកោសល្យគំរូត្រូវផលិតឱ្យបាននូវឯកសារបង្រៀនសម្បូរបែបផងដែរដូចជា សៀវភៅមេរៀនមុខវិជ្ជាឯកទេស គរុកោសល្យ វិធីសាស្ត្របង្រៀនថ្មីៗ សៀវភៅលំហាត់។ល។ ក្នុងន័យនេះ សាលាគរុកោសល្យត្រូវរៀបចំឱ្យមានប្រព័ន្ធលើកទឹកចិត្តដល់បុគ្គលិកអប់រំ ពិសេសគ្រូឧទ្ទេសធ្វើការនិពន្ធ ចងក្រង ឯកសារបង្រៀនរបស់ខ្លួន និងសៀវភៅខ្លឹមសារដទៃទៀតផងដែរដែលគ្រូឧទ្ទេសមានសមត្ថភាពអាចធ្វើបាន។ លើសពីនេះ ត្រូវគាំទ្រ និងលើកសរសើរស្នាដៃរបស់គ្រូឧទ្ទេស ដោយសម្របសម្រួលបោះពុម្ពផ្សាយ រក្សាទុកនៅបណ្ណាល័យ សម្រាប់អ្នកសិក្សាប្រើប្រាស់ជាពិសេសគរុសិស្ស គរុនិស្សិត។

## ៧. ការវាយតម្លៃស្តង់ដាសាលាគរុកោសល្យគំរូ

### ៧.១. ឧបករណ៍វាយតម្លៃស្តង់ដាសាលាគរុកោសល្យគំរូ

ឧបករណ៍វាយតម្លៃស្តង់ដាសាលាគរុកោសល្យគំរូ ត្រូវបានអភិវឌ្ឍឡើងដោយផ្អែកលើស្តង់ដា និងសូចនាករទាំងឡាយដូចមានបង្ហាញនៅក្នុងតារាងស្តង់ដា និងសូចនាករខាងលើ។ សូចនាករនីមួយៗនៃស្តង់ដានឹងត្រូវត្រួតពិនិត្យវាយតម្លៃជាពិន្ទុអាស្រ័យដោយភស្តុតាងជាក់ស្តែង។ ឧបករណ៍វាយតម្លៃនេះ នឹងត្រូវប្រើប្រាស់ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ដើម្បីវាយតម្លៃកម្រិតសម្រេចបានរបស់សាលាគរុកោសល្យ។

*ការវាយតម្លៃនេះ មិនសំដៅដាក់ពិន័យ ឬទណ្ឌកម្មចំពោះគណៈគ្រប់គ្រង បុគ្គលិកអប់រំ គ្រូឧទ្ទេស គរុសិស្ស គរុនិស្សិត ឬអ្នកពាក់ព័ន្ធនានា នៃសាលាគរុកោសល្យឡើយ។ ការវាយតម្លៃនេះ ជារង្វាស់ដែលបង្ហាញពីទឡ្ហីករ សម្រេចបានរបស់សាលាគរុកោសល្យ និងជាមូលដ្ឋានសម្រាប់ចង្អុលបង្ហាញទិសដៅអភិវឌ្ឍនិងកែលម្អរបស់សាលាគរុកោសល្យឱ្យកាន់តែប្រសើរឡើងថែមទៀត។*

### ៧.២. របៀបវាយតម្លៃស្តង់ដាសាលាគរុកោសល្យគំរូ

ដើម្បីធានាបាននូវការវាយតម្លៃប្រកបដោយគុណភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់ អ្នកពាក់ព័ន្ធត្រូវអនុវត្តដូចខាងក្រោម៖

- ស្វ័យវាយតម្លៃជាប្រចាំ ទៅតាមស្តង់ដា និងសូចនាករ ដូចមាននៅក្នុងស្តង់ដានេះ
- រៀបចំរបាយការណ៍ស្វ័យវាយតម្លៃឱ្យបានគត់មត់ភ្ជាប់ជាមួយឯកសារភស្តុតាងពាក់ព័ន្ធឱ្យបានច្បាស់លាស់ រួចបញ្ជូនទៅក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំគណៈកម្មការវាយតម្លៃ ដោយមានការចូលរួមពីអង្គភាពពាក់ព័ន្ធ ដើម្បីចុះពិនិត្យ វាយតម្លៃ ផ្ទៀងផ្ទាត់នៅសាលាគរុកោសល្យដោយផ្ទាល់ ដោយផ្អែកលើរបាយការណ៍ស្វ័យវាយតម្លៃ
- គណៈកម្មការវាយតម្លៃ ត្រូវរៀបចំបូកសរុបលទ្ធផលវាយតម្លៃ និងធ្វើចំណាត់ថ្នាក់ពិន្ទុ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យ និងសម្រេច
- ក្របខណ្ឌពេលវេលានៃការចុះវាយតម្លៃ ត្រូវកំណត់ដោយសេចក្តីណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៨. បែបបទ និងនីតិវិធីនៃការវាយតម្លៃស្តង់ដាសាលាគរុកោសល្យគំរូ

### ៨.១. គោលការណ៍ទូទៅ និងលក្ខណៈវិនិច្ឆ័យ

ការវាយតម្លៃផ្តល់ជាសាលាគរុកោសល្យគំរូត្រូវផ្អែកលើវឌ្ឍនភាព និងការរីកចម្រើន របស់សាលាគរុកោសល្យ និងត្រូវធ្វើការវាយតម្លៃជារៀងរាល់ចុងឆ្នាំសិក្សានីមួយៗ។ លក្ខណៈវិនិច្ឆ័យ និងឧបករណ៍វាយតម្លៃទទួលស្គាល់សាលាគរុកោសល្យគំរូ ជាឧបសម្ព័ន្ធនៃឯកសារនេះ។

### ៨.២. យន្តការ បែបបទ និងនីតិវិធី

#### ក. កម្រិតសាលាគរុកោសល្យ

១. គណៈគ្រប់គ្រងសាលាគរុកោសល្យត្រូវរៀបចំគណៈកម្មការវាយតម្លៃផ្ទៃក្នុង និងធ្វើការជាមួយផ្នែកពាក់ព័ន្ធផ្ទៃក្នុងនានា ដើម្បីធ្វើស្វ័យវាយតម្លៃ រួចរៀបចំរបាយការណ៍ស្វ័យវាយតម្លៃឱ្យបានគត់មត់ ដោយមានភ្ជាប់ជាមួយឯកសារជាភស្តុតាងពាក់ព័ន្ធឱ្យបានច្បាស់លាស់

២. គណៈគ្រប់គ្រងសាលាគរុកោសល្យត្រូវដាក់ពាក្យស្នើសុំធ្វើការវាយតម្លៃមកក្រសួងអប់រំ យុវជន និងកីឡា ដោយរៀបចំសំណុំឯកសារដូចខាងក្រោម៖

- ពាក្យសុំវាយតម្លៃជាសាលាគរុកោសល្យគំរូ ..................................................០៣ច្បាប់
- របាយការណ៍ស្វ័យវាយតម្លៃ....................................................................០៣ច្បាប់
- កំណត់ហេតុប្រជុំ និងបញ្ជីវត្តមានប្រជុំស្វ័យវាយតម្លៃ .....................................០៣ច្បាប់
- សំណុំឯកសារពាក់ព័ន្ធ ភស្តុតាងនានា (អាចជាឯកសារ រូបថត ឬវីដេអូ) ...........០៣ច្បាប់

#### ខ. កម្រិតក្រសួងអប់រំ យុវជន និងកីឡា

១. ដោយផ្អែកលើរបាយការណ៍ស្វ័យវាយតម្លៃរបស់សាលាគរុកោសល្យ ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំសេចក្តីសម្រេចបង្កើតគណៈកម្មការវាយតម្លៃ ដោយមានការចូលរួមពីអង្គភាពពាក់ព័ន្ធ ដើម្បីចុះសិក្សា ពិនិត្យ វាយតម្លៃ ផ្ទៀងផ្ទាត់នៅសាលាគរុកោសល្យដោយផ្ទាល់

២. គណៈកម្មការវាយតម្លៃ ត្រូវរៀបចំបូកសរុបលទ្ធផលវាយតម្លៃ និងធ្វើចំណាត់ថ្នាក់ពិន្ទុ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យ និងសម្រេច។

## ៩. សេចក្តីសន្និដ្ឋាន

ស្តង់ដាសាលាគរុកោសល្យគំរូ ដែលបានរៀបចំឡើងនេះ នឹងត្រូវប្រើប្រាស់ ដើម្បីជាគុណប្រយោជន៍ក្នុងការជំរុញការអភិវឌ្ឍ និងកែលម្អសាលាគរុកោសល្យឱ្យកាន់តែមានគុណភាពប្រសើរឡើង ក្នុងក្របខណ្ឌតួនាទីស្នូលរបស់ខ្លួនគឺការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា ស្តង់ដាសាលាគរុកោសល្យគំរូនេះ នឹងជួយដល់សាលាគរុកោសល្យទាំងអស់ក្នុងប្រទេសកម្ពុជាក្នុងការកំណត់ទិសដៅ និងរៀបចំផែនការយុទ្ធសាស្ត្រ អភិវឌ្ឍគ្រឹះស្ថានរបស់ខ្លួនឱ្យបានឆាប់រហ័ស ឆ្លើយតបនឹងគោលនយោបាយកំណែទម្រង់អាទិភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា និងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។

## ឧបសម្ព័ន្ធ៖ បែបបទនិងនីតិវិធីនៃការវាយតម្លៃសាលាគរុកោសល្យគំរូ

### I. ព័ត៌មានទូទៅ

1. រាជធានី ខេត្ត ៖ ..............................................................................
2. សាលាគរុកោសល្យ ៖ ..............................................................................
3. ឈ្មោះនាយក ៖ ..............................................................................
4. លេខទូរស័ព្ទនាយក ៖ ..............................................................................
5. ថ្ងៃខែឆ្នាំពិនិត្យនិងវាយតម្លៃ ៖ ..............................................................................
6. អ្នកពិនិត្យនិងវាយតម្លៃ ៖ ..............................................................................
7. លេខទូរស័ព្ទអ្នកពិនិត្យនិងវាយតម្លៃ ៖ ..............................................................................

## II. នីតិវិធីនៃការវាយតម្លៃសាលាគរុកោសល្យគំរូ

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| **ស្តង់ដាទី១ ៖ លទ្ធផលបណ្តុះបណ្តាល** | | | | | | | |
| ១.១. គុណសម្បទាគ្រូបង្រៀនដែលបានបញ្ចប់ការបណ្តុះបណ្តាល | | | | | | | |
| ១.១.១ | ភាពជាគ្រូបង្រៀន | ១. ចំណេះដឹងស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន<br>២. ការប្រតិបត្តិវិជ្ជាជីវៈស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន<br>៣. ការអនុវត្តគន្លងអាជីព<br>៤. ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>៥. ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន | ៧០-៧៥%<br>មាន១ចំណុច | ៧០-៧៥%<br>មាន២ចំណុច | ៧០-៧៥%<br>មាន៣ចំណុច | ៧០-៧៥%<br>មាន៤ចំណុច | ៧០-៧៥%<br>មាន៥ចំណុច |
| ១.១.២ | ការទទួលស្គាល់ | ១. ការទទួលស្គាល់ពីនាយកសាលា<br>២. ការទទួលស្គាល់ពីសហការី<br>៣. ការទទួលស្គាល់ពីសិស្ស<br>៤. ការទទួលស្គាល់ពីមាតា បិតាសិស្ស<br>៥. ការទទួលស្គាល់ពីសហគមន៍ | ៧០-៧៥%<br>មាន១ចំណុច | ៧០-៧៥%<br>មាន២ចំណុច | ៧០-៧៥%<br>មាន៣ចំណុច | ៧០-៧៥%<br>មាន៤ចំណុច | ៧០-៧៥%<br>មាន៥ចំណុច |
| ១.១.៣ | ការគាំទ្រសាលារៀនដែលកំពុងបម្រើការឱ្យក្លាយជាសាលារៀនគំរូ | ១. ការចែករំលែកចំណេះដឹងទាក់ទងនឹងវិធីសាស្ត្របង្រៀនថ្មី<br>២. ការចែករំលែកចំណេះដឹងទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល<br>៣. ការចែករំលែកចំណេះដឹងទាក់ទងនឹងការស្រាវជ្រាវប្រតិបត្តិ<br>៤. ការគាំទ្រគ្រូបង្រៀនអភិវឌ្ឍនិងអនុវត្តតេស្តស្តង់ដាក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សដោយផ្តោតលើ តេស្ត PISA និង SEA-PLM<br>៥. ការទទួលខុសត្រូវលើតួនាទីនិងបំណែងចែកភារកិច្ច | ៧០-៧៥%<br>មាន១ចំណុច | ៧០-៧៥%<br>មាន២ចំណុច | ៧០-៧៥%<br>មាន៣ចំណុច | ៧០-៧៥%<br>មាន៤ចំណុច | ៧០-៧៥%<br>មាន៥ចំណុច |
| ១.២. លទ្ធផលសិក្សារបស់គរុនិស្សិត គរុនិស្សិត | | | | | | | |
| ១.២.១ | លទ្ធផលវាយតម្លៃលើមុខវិជ្ជាសិក្សា | ភាគរយគរុសិស្ស គរុនិស្សិតទទួលបានពិន្ទុចាប់ពី ៧៥-១០០ លើការវាយតម្លៃមុខវិជ្ជាសិក្សា | ៥០-៥៩% | ៦០-៦៩% | ៧០-៧៩% | ៨០-៨៩% | ≥ ៩០ |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| ១.២.២ | លទ្ធផលវាយតម្លៃកម្មសិក្សាគរុកោសល្យ | ភាគរយគរុសិស្ស គរុនិស្សិតទទួលបានពិន្ទុចាប់ពី ៧៥-១០០ លើការវាយតម្លៃកម្មសិក្សាគរុកោសល្យឆ្នាំចុងក្រោយនៃកម្មវិធីបណ្តុះបណ្តាល | ៥០-៥៩% | ៦០-៦៩% | ៧០-៧៩% | ៨០-៨៩% | ≥ ៩០ |
| ១.២.៣ | លទ្ធផលវាយតម្លៃគម្រោងស្រាវជ្រាវប្រតិបត្តិ | ភាគរយគរុសិស្ស គរុនិស្សិតដែលបានការពារនិងសរសេររបាយកាណ៍ស្រាវជ្រាវប្រតិបត្តិបញ្ចប់ដោយជោគជ័យ | ៥០-៥៩% | ៦០-៦៩% | ៧០-៧៩% | ៨០-៨៩% | ≥ ៩០ |
| ១.២.៤ | ការអនុវត្ត PISA / SEA-PLM /តេស្តស្តង់ដាក្នុងអំឡុងពេលកម្មសិក្សាគរុកោសល្យ | ភាគរយ គរុសិស្ស គរុនិស្សិតដែលបានអនុវត្ត PISA / SEA-PLM/ តេស្តស្តង់ដា ក្នុងអំឡុងពេលកម្មសិក្សាគរុកោសល្យ | ៦០-៦៩% | ៧០-៧៩% | ៨០-៨៩% | ៩០-៩៩% | ១០០% |
| ១.២.៥ | ចំណេះដឹងភាសាបរទេស | ភាគរយ គរុសិស្ស គរុនិស្សិតដែលមានចំណេះដឹងភាសាបរទេសកម្រិតមធ្យម ( Intermediate ) | ៥០-៥៩% | ៦០-៦៩% | ៧០-៧៩% | ៨០-៨៩% | ≥ ៩០ |
| ១.២.៦ | ចំណេះដឹង ICT | ភាគរយគរុសិស្ស គរុនិស្សិតដែលមានចំណេះដឹង ICT សម្រាប់ការងាររដ្ឋបាល និង ICT ក្នុងការអប់រំ កម្រិតមធ្យម ( Intermediate ) | ៥០-៥៩% | ៦០-៦៩% | ៧០-៧៩% | ៨០-៨៩% | ≥ ៩០ |
| ១.២.៧ | សមត្ថភាពគរុសិស្ស គរុនិស្សិតដែលបញ្ចប់ការបណ្តុះបណ្តាលធៀបនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន | ភាគរយគរុសិស្ស គរុនិស្សិតដែលមានសមត្ថភាពឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនតាមរយៈការវាយតម្លៃលើសមត្ថភាពអប់រំគរុសិស្ស គរុនិស្សិត ( Student Teacher Education Competency ) ឆ្នាំចុងក្រោយ | ៦០-៦៩% | ៧០-៧៩% | ៨០-៨៩% | ៩០-៩៩% | ១០០% |
| ១.២.៨ | លទ្ធផលប្រឡងបញ្ចប់ | ភាគរយគរុសិស្ស គរុនិស្សិតប្រឡងបញ្ចប់ជាប់ជាស្ថាពរដែលទទួលបានពិន្ទុចាប់ពី ៧៥-១០០ | ៦០-៦៩% | ៧០-៧៩% | ៨០-៨៩% | ៩០-៩៩% | ១០០% |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | ការម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| **ស្តង់ដាទី២ ៖ ធនធានបណ្តុះបណ្តាល** | | | | | | | |
| ២.១. ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | | | | | | | |
| ២.១.១ | ហេដ្ឋារចនា<br>សម្ព័ន្ធ | ១. ប្លង់មេ<br>២. អគារសិក្សា<br>៣. បណ្ណាល័យ<br>៤. បន្ទប់ពិសោធន៍<br>៥. អគាររដ្ឋបាល<br>៦. សាលពហុបំណង<br>៧. អន្តេវាសិកដ្ឋានគរុសិស្ស គរុនិស្សិត<br>៨. អន្តេវាសិកដ្ឋានគ្រូឧទ្ទេស<br>៩. រោងជាង-គេហកិច្ច<br>១០. អាហារដ្ឋាន<br>១១. ឃ្លាំងសម្ភារៈ<br>១២. ទីលានកីឡា<br>១៣. ទីលានអត្តពលកម្ម<br>១៤. សួនបំណិនជីវិត<br>១៥. សួនច្បារ<br>១៦. ខ្លោងទ្វារ និងរបង<br>១៧. បណ្តាញប្រព័ន្ធ (ទឹក ភ្លើង ផ្លូវ លូ)<br>១៨. ប្រព័ន្ធសុវត្ថិភាព ប្រព័ន្ធបច្ចេកវិទ្យា ប្រព័ន្ធទំនាក់ទំនង<br>១៩. ចំណតយានជំនិះ<br>២០. ជម្រាលជនមានពិការភាព | មាន១២ចំណុច | មាន១៤ចំណុច | មាន១៦ចំណុច | មាន១៨ចំណុច | មាន២០ចំណុច |
| ២.១.២ | បន្ទប់សិក្សា | ១. គ្រឿងសង្ហារឹម<br>២. សម្ភារៈសិក្សា<br>៣. សម្ភារៈបច្ចេកវិទ្យាព័ត៌មានចាំបាច់សម្រាប់ការបង្រៀននិងរៀន (LCD/ក្តារខៀនឆ្លាតវៃ កុំព្យូទ័រ ។ល។) | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | ការម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| | | ៤. សេវាអ៊ិនធឺណិត<br>៥. ផាសុកភាព (ពន្លឺ ម៉ាស៊ីនត្រជាក់ ខ្យល់អាកាស) | | | | | |
| ២.១.៣ | បន្ទប់គ្រូឧទ្ទេស | ១. បន្ទប់ដាច់ដោយឡែកសម្រាប់ដេប៉ាតឺម៉ង់/មុខវិជ្ជា<br>២. សម្ភារៈបច្ចេកវិទ្យាព័ត៌មានចាំបាច់<br>៣. តុបំពេញការងារសម្រាប់គ្រូឧទ្ទេសម្នាក់ៗ<br>៤. សេវាអ៊ិនធឺណិត<br>៥. កន្លែងសម្រាប់ប្រជុំ<br>៦. ទូររក្សាឯកសារ | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច | មាន៦ចំណុច |
| ២.១.៤ | បណ្ណាល័យ | ១. ទីតាំង និងបរិវេណ<br>២. ការរៀបចំបរិវេណ<br>៣. លទ្ធភាពប្រើប្រាស់រូបវន្ត និងឌីជីថល<br>៤. បណ្ណាល័យទូរនិមិត្ត (e-library)<br>៥. លក្ខខណ្ឌតម្រូវបុគ្គលិកសម្រាប់បណ្ណាល័យ<br>៦. គុណវុឌ្ឍិបណ្ណារក្ស<br>៧. តួនាទីបណ្ណារក្សក្នុងការគាំទ្របណ្ណាល័យសតវត្សទី២១<br>៨. ការរៀបចំផែនការ និងការផ្សព្វផ្សាយ<br>៩. សេវាទាក់ទងនឹងសមូហកម្មសៀវភៅ<br>១០. សេវាឌីជីថល<br>១១. កម្មវិធីពិសេសដើម្បីឆ្លើយតបតាមគោលដៅនិងចក្ខុវិស័យរបស់គ្រឹះស្ថាន<br>១២. សេវាអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន<br>១៣. បំណែងចែកភារកិច្ច<br>១៤. ម៉ោងប្រតិបត្តិការ<br>១៥. បទបញ្ជាទាំងឡាយសម្រាប់អ្នកប្រើប្រាស់<br>១៦. ការត្រួតពិនិត្យ/ការគ្រប់គ្រងការប្រើប្រាស់សៀវភៅនិងឌីជីថល | មាន៨ចំណុច | មាន១០ចំណុច | មាន១២ចំណុច | មាន១៤ចំណុច | មាន១៦ចំណុច |
| ២.១.៥ | បន្ទប់ពិសោធន៍ | ១. បន្ទប់ពិសោធន៍ដាច់ដោយឡែកសម្រាប់មុខវិជ្ជានីមួយៗ (គណិតវិទ្យា វិទ្យាសាស្ត្រ និងសិក្សាសង្គម) | | | | | |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| | | ២. សម្ភារៈពិសោធន៍ចាំបាច់សម្រាប់ការបង្រៀននិងរៀន<br>៣. សេវាអ៊ិនធឺណិតគ្រប់បន្ទប់<br>៤. LCD/ក្តារខៀនឆ្លាតវៃ/ទូរទស្សន៍ឆ្លាតវៃ កុំព្យូទ័រ និងសម្ភារៈបច្ចេកវិទ្យាព័ត៌មានចាំបាច់<br>៥. សៀវភៅណែនាំស្តីពី សុវត្ថិភាពក្នុងបន្ទប់ពិសោធន៍ | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| ២.១.៦ | បន្ទប់ ICT | ១. បន្ទប់ ICT ដាច់ដោយឡែក<br>២. កុំព្យូទ័រគ្រប់គ្រាន់សម្រាប់ការបង្រៀននិងរៀន<br>៣. សេវាអ៊ិនធឺណិត<br>៤. LCD/ក្តារខៀនឆ្លាតវៃ/ទូរទស្សន៍ឆ្លាតវៃ កុំព្យូទ័រ និងសម្ភារៈបច្ចេកវិទ្យាព័ត៌មានចាំបាច់<br>៥. សៀវភៅណែនាំស្តីពី ការប្រើប្រាស់បន្ទប់ ICT | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| ២.១.៧ | បន្ទប់សុខភាព | ១. សម្ភារៈសុខភាព (ស្តង់ដាកញ្ចប់សម្ភារៈសុខភាព)<br>២. សៀវភៅតាមដានសុខភាពសម្រាប់គរុសិស្ស គរុនិស្សិត<br>៣. ផែនការនិងប្រតិបត្តិការបន្ទប់សុខភាព | - | - | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច |
| ២.១.៨ | បន្ទប់សិល្បៈប្រពៃណី | ១. សម្ភារៈសិល្បៈប្រពៃណី<br>២. ផែនការនិងការអនុវត្តសកម្មភាពសិល្បៈប្រពៃណី | - | - | - | មាន១ចំណុច | មាន២ចំណុច |
| ២.១.៩ | សាលាគរុកោសល្យបៃតង/មេត្រី | ១. ពុំមានសំរាម<br>២. ពុំមានផ្សែងបារី<br>៣. ពុំមានការប្រើប្រាស់គ្រឿងញៀន<br>៤. ពុំមានគ្រឿងស្រវឹង<br>៥. ពុំមានការបៀតបៀន<br>៦. ពុំមានការរើសអើង<br>៧. ពុំមានការគំរាមកំហែង<br>៨. ពុំមានអំពើហឹង្សា | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច | មាន៦ចំណុច | មាន៧ចំណុច |

| ល.រ | សូចនាករ | ចំណុចត្រួតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| ២.១.១០ | ការថែទាំហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ និង បរិស្ថាន | ភាគរយហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ និងបរិស្ថានទទួលបានការថែទាំតាមលក្ខណៈបច្ចេកទេស | ៥០-៥៩% | ៦០-៦៩% | ៧០-៧៩% | ៨០-៨៩% | ≥ ៩០ |
| **២.២. ធនធានមនុស្ស** | | | | | | | |
| ២.២.១ | កម្រិតគុណវុឌ្ឍិ | ភាគរយគ្រូឧទ្ទេសមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ | ១០-១៩% | ២០-២៩% | ៣០-៣៩% | ៤០-៤៩% | ≥៥០% |
| ២.២.២ | កម្រិតវិជ្ជាជីវៈ | ភាគរយគ្រូឧទ្ទេសឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស | ៥០-៥៩% | ៦០-៦៩% | ៧០-៧៩% | ៨០-៨៩% | ≥ ៩០ |
| ២.២.៣ | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ១. ការអនុវត្តការសិក្សាស្រាវជ្រាវមេរៀនជាប្រចាំ<br>២. ការចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ<br>៣. ការរៀបចំផែនការសិក្សាវិជ្ជាជីវៈ<br>៤. ការចូលវគ្គបំប៉ន សិក្ខាសាលា ឬសន្និសីទ<br>៥. ការដំឡើងគុណវុឌ្ឍិ | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| **២.៣. កម្មវិធីបណ្តុះបណ្តាល** | | | | | | | |
| ២.៣.១ | កម្មវិធីនិងឯកសារបណ្តុះបណ្តាល | ១. ក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន<br>២. កម្មវិធីបណ្តុះបណ្តាលលម្អិត<br>៣. ឯកសារបង្រៀននិងរៀន<br>៤. កញ្ចប់អំណាននិងគណិតវិទ្យាថ្នាក់ដំបូង PISA SEA-PLM ឬតេស្តស្តង់ដា<br>៥. សម្ភារឧបទេស<br>៦. កិច្ចតែងការបង្រៀន<br>៧. វិធីសាស្ត្របង្រៀន<br>៨. ឯកសារសម្រាប់សិក្សាស្រាវជ្រាវបន្ថែម<br>៩. ការប្រើប្រាស់ ICT និងបច្ចេកវិទ្យាឌីជីថលនៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន | មាន៥ចំណុច | មាន៦ចំណុច | មាន៧ចំណុច | មាន៨ចំណុច | មាន៩ចំណុច |
| ២.៣.២ | ផែនការបណ្តុះបណ្តាល | ១. ផែនការបណ្តុះបណ្តាលប្រចាំខែ<br>២. ផែនការបណ្តុះបណ្តាលប្រចាំឆមាស<br>៣. ផែនការបណ្តុះបណ្តាលប្រចាំឆ្នាំ<br>៤. កាលវិភាគបង្រៀនតាមមុខវិជ្ជា | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច | មាន៦ចំណុច |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| | | ៥. តារាងបែងចែកគ្រូឧទ្ទេសបង្រៀន<br>៦. បទប្បញ្ញត្តិបណ្តុះបណ្តាល | | | | | |
| ២.៣.៣ | ការពិនិត្យតាមដានការអនុវត្តកម្មវិធីបណ្តុះបណ្តាល | ១. គណៈកម្មការពិនិត្យតាមដាន<br>២. ផែនការពិនិត្យតាមដានការបង្រៀន<br>៣. ឧបករណ៍ពិនិត្យតាមដានការបង្រៀន<br>៤. អធិការកិច្ចការបង្រៀនរបស់គ្រូឧទ្ទេស<br>៥. របាយការណ៍អធិការកិច្ច | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| ២.៣.៤ | កម្មសិក្សាគរុកោសល្យ | ១. គណៈកម្មការកម្មសិក្សាគរុកោសល្យ<br>២. សៀវភៅណែនាំកម្មសិក្សាគរុកោសល្យ<br>៣. កាលវិភាគកម្មសិក្សាគរុកោសល្យ<br>៤. ឧបករណ៍វាយតម្លៃដាក់ពិន្ទុផ្អែកលើភស្តុតាង<br>៥. របាយការណ៍វាយតម្លៃកម្មសិក្សាគរុកោសល្យ | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| ២.៣.៥ | សកម្មភាពក្រៅកម្មវិធីបណ្តុះបណ្តាល | ១. បាឋកថា (អប់រំសីលធម៌ សុជីវធម៌ ចរិយាធម៌ ។ល។)<br>២. កម្មវិធីផ្លាស់ប្តូរគរុសិស្ស គរុនិស្សិតជាមួយគ្រឹះស្ថានអប់រំក្នុងឬក្រៅប្រទេស<br>៣. ក្លឹបសិក្សា (សិល្បៈ កីឡា យុវជន ការងារសប្បុរសធម៌ ។ល។)<br>៤. កម្មវិធីវប្បធម៌ ប្រពៃណីជាតិផ្សេងៗ<br>៥. ការធ្វើពលកម្មសម្អាតបរិស្ថានគ្រឹះស្ថាន<br>៦. ទស្សនកិច្ចសិក្សា<br>៧. ភាសាបរទេស<br>៨. ICT | មាន៤ចំណុច | មាន៥ចំណុច | មាន៦ចំណុច | មាន៧ចំណុច | មាន៨ចំណុច |
| **២.៤. វិក្រឹតការគ្រូបង្រៀន** | | | | | | | |
| ២.៤.១ | ការទទួលស្គាល់ជាអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | ១. ការស្នើសុំការទទួលស្គាល់ជាគ្រឹះស្ថានផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>២. ការទទួលស្គាល់ជាគ្រឹះស្ថានផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពីការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀងផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| | | ៣. វគ្គសិក្សាសម្រាប់ការផ្តល់សេវាអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>៤. វគ្គសិក្សាដែលបានទទួលស្គាល់គុណភាពពីការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ<br>៥. សិក្ខាកាមបញ្ចប់វគ្គសិក្សាទទួលបានក្រេឌីតដែលបានកត់ត្រាក្នុងប្រព័ន្ធ HRMIS | | | | | |
| ២.៤.២ | ការដំឡើងគុណវុឌ្ឍិ | ១. ក្របខណ្ឌកម្មវិធីដំឡើងគុណវុឌ្ឍិ<br>២. កម្មវិធីបណ្តុះបណ្តាលលម្អិត<br>៣. ខ្លឹមសារមេរៀន<br>៤. សម្ភារឧបទេស<br>៥. គ្រូឧទ្ទេសមានគុណវុឌ្ឍិស្របតាមស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| **ស្តង់ដាទី៣ ៖ កិច្ចសហប្រតិបត្តិការ** | | | | | | | |
| ៣.១. ការផ្សារភ្ជាប់សាលាគរុកោសល្យនិងសាលាអនុវត្តន៍ | | | | | | | |
| ៣.១.១ | ផែនការចុះគាំទ្រសាលាអនុវត្តន៍ | ១. គណៈកម្មការចុះជួយគាំទ្រសាលាអនុវត្តន៍<br>២. ផែនការចុះជួយគាំទ្រសាលាអនុវត្តន៍<br>៣. បំណែងចែកតួនាទី ភារកិច្ច<br>៤. ការចុះជួយសាលាអនុវត្តន៍តាមផែនការ<br>៥. របាយការណ៍លទ្ធផលស្តីពីការចុះជួយគាំទ្រ | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| ៣.១.២ | ការគាំទ្រលើការដឹកនាំនិងគ្រប់គ្រង | ១. ការដឹកនាំធ្វើផែនការអភិវឌ្ឍន៍សាលារៀន<br>២. ការដឹកនាំធ្វើផែនការថវិកា ៣ឆ្នាំ<br>៣. ការដឹកនាំធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំ<br>៤. ឧបករណ៍ពិនិត្យតាមដាន វាយតម្លៃការដឹកនាំនិងគ្រប់គ្រង<br>៥. ការពិនិត្យតាមដាន វាយតម្លៃជាប្រចាំលើការដឹកនាំ និងគ្រប់គ្រង<br>៦. ការផ្តល់ព័ត៌មានត្រឡប់និងតម្រង់ទិសដល់គណៈគ្រប់គ្រងសាលារៀន | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច | មាន៦ចំណុច |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| ៣.១.៣ | ការគាំទ្រលើការអនុវត្តកម្មវិធីសិក្សា | ១. គ្រូបង្រៀនទាំងអស់មានក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស<br>២. គ្រូបង្រៀនទាំងអស់មានកម្មវិធីសិក្សាលម្អិត<br>៣. ការគាំទ្រដល់គ្រូបង្រៀនក្នុងការរៀបចំផែនការបង្រៀនតាមមុខវិជ្ជាប្រចាំឆមាសនិងប្រចាំឆ្នាំ<br>៤. គ្រូបង្រៀនទាំងអស់មានកាលវិភាគបង្រៀនប្រចាំសប្តាហ៍<br>៥. គ្រូបង្រៀនទាំងអស់មានកិច្ចតែងការបង្រៀនគ្រប់មេរៀន<br>៦. ការគាំទ្រគ្រូបង្រៀនក្នុងការផលិតសម្ភារឧបទេស<br>៧. ការគាំទ្រគ្រូបង្រៀនក្នុងការប្រើប្រាស់សម្ភារឧបទេស<br>៨. ការគាំទ្រគ្រូបង្រៀនក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍<br>៩. ការគាំទ្រគ្រូបង្រៀនក្នុងការប្រើប្រាស់បណ្ណាល័យ | មាន២ចំណុច | មាន៣ចំណុច | មាន៥ចំណុច | មាន៧ចំណុច | មាន៩ចំណុច |
| ៣.១.៤ | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀនសាលាអនុវត្តន៍ | ១. ការសិក្សាពីតម្រូវការ ការអភិវឌ្ឍវិជ្ជាជីវៈ<br>២. ការដឹកនាំគ្រូបង្រៀនរៀបចំផែនការសិក្សាវិជ្ជាជីវៈ<br>៣. ការគាំទ្រគ្រូបង្រៀនក្នុងការស្វែងរកវគ្គសិក្សានានាក្នុង HRCPD<br>៤. ការបំប៉នវិធីសាស្ត្របង្រៀនថ្មីដល់គ្រូបង្រៀនសាលាអនុវត្តន៍<br>៥. ការផ្តល់ប្រឹក្សាគរុកោសល្យជាប្រចាំដល់គ្រូបង្រៀន<br>៦. ការរៀបចំផែនការ ការសិក្សាស្រាវជ្រាវមេរៀន<br>៧. គ្រូបង្រៀនចូលរួមការសិក្សាស្រាវជ្រាវមេរៀន ជាមួយ គ្រូឧទ្ទេសតាមផែនការ<br>៨. ការចុះសង្កេតការបង្រៀនរបស់គ្រូបង្រៀននិងផ្តល់ព័ត៌មានត្រឡប់ | មាន៤ចំណុច | មាន៥ចំណុច | មាន៦ចំណុច | មាន៧ចំណុច | មាន៨ចំណុច |
| **៣.២. កិច្ចសហប្រតិបត្តិការជាមួយសហគមន៍ គ្រឹះស្ថានអប់រំ និងដៃគូអភិវឌ្ឍ** | | | | | | | |
| ៣.២.១ | ការចូលរួមកិច្ចការសហគមន៍ | ១. ការចូលរួមគាំទ្រដល់កិច្ចការសង្គមផ្សេងៗដូចជា ការងារសប្បុរសធម៌ សកម្មភាពកាកបាទក្រហម | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |

| ល.រ | សូចនាករ | ចំណុចត្រួតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| | | ២. ការចូលរួមសកម្មភាពវប្បធម៌ប្រពៃណី ការងារបរិស្ថាន ដាំដើមឈើ ការគាំពារសុខភាពសង្គម។ល។<br>៣. ការរៀបចំតាំងបង្ហាញពិព័រណ៍ស្នាដៃគ្រូឧទ្ទេសនិងគរុសិស្សគរុនិស្សិតប្រចាំឆ្នាំ<br>៤. ការចូលរួមធ្វើបទបង្ហាញចែករំលែកបទពិសោធដល់សហគមន៍<br>៥. ការចែករំលែកចំណេះដឹងដល់សហគមន៍ | | | | | |
| ៣.២.២ | ការស្វែងរកការគាំទ្រពីសហគមន៍ និងដៃគូអភិវឌ្ឍ | ១. ការផ្សព្វផ្សាយពីផែនការយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន<br>២. ការស្វែងរកការគាំទ្រពីសហគមន៍ដើម្បីគាំទ្រការអនុវត្តផែនការយុទ្ធសាស្ត្រ<br>៣. ការស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍ<br>៤. ការទទួលបានការគាំទ្រពីសហគមន៍<br>៥. ការទទួលបានការគាំទ្រពីដៃគូអភិវឌ្ឍ | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| ៣.២.៣ | កិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានអប់រំក្នុងប្រទេស | ចំនួនគ្រឹះស្ថានអប់រំក្នុងប្រទេសដែលបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការ | ១ | ២ | ៣ | ៤ | ≥ ៥ |
| ៣.២.៤ | កិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានអប់រំក្រៅប្រទេស | ចំនួនគ្រឹះស្ថានអប់រំក្រៅប្រទេសដែលបានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការ | ១ | ២ | ៣ | ៤ | ≥ ៥ |
| ៣.២.៥ | ការចុះគាំទ្រការធ្វើកំណែទម្រង់សាលារៀនឆ្ពោះទៅការសម្រេចបានជាសាលារៀនគំរូ | ចំនួនសាលារៀនដែលបានចុះគាំទ្រនិងទទួលស្គាល់ជាសាលារៀនគំរូ | ១ | ២ | ៣ | ៤ | ≥ ៥ |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| **ស្តង់ដាទី៤ ៖ អភិបាលកិច្ចល្អ** | | | | | | | |
| **៤.១. ការដឹកនាំ និងគ្រប់គ្រង** | | | | | | | |
| ៤.១.១ | ប្រព័ន្ធដឹកនាំនិងគ្រប់គ្រង | ១. រចនាសម្ព័ន្ធគ្រប់គ្រង<br>២. បំណែងចែកតួនាទី ភារកិច្ច<br>៣. ក្រុមប្រឹក្សាបច្ចេកទេស (ក្រុមប្រឹក្សាភិបាល/ក្រុមប្រឹក្សាពិគ្រោះយោបល់)<br>៤. ក្រុមប្រឹក្សាអប់រំ/ ក្រុមប្រឹក្សាវិទ្យាសាស្ត្រ<br>៥. ក្រុមប្រឹក្សាគរុកោសល្យ<br>៦. គណៈវគ្គ/គណៈកម្មការយុវជន | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច | មាន៦ចំណុច |
| ៤.១.២ | ផែនការអភិវឌ្ឍន៍គ្រឹះស្ថាន | ១. ផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ<br>២. ផែនការយុទ្ធសាស្ត្រថវិកា ៣ឆ្នាំ<br>៣. ផែនការប្រតិបត្តិប្រចាំឆ្នាំ<br>៤. របាយការណ៍វឌ្ឍនភាព<br>៥. របាយការណ៍លទ្ធផល (សមិទ្ធកម្ម) សម្រេចបានប្រចាំឆ្នាំ | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| ៤.១.៣ | ការគ្រប់គ្រងទិន្នន័យគ្រឹះស្ថាន | ១. ប្រព័ន្ធគ្រប់គ្រងទិន្នន័យសារពើភ័ណ្ឌ ទ្រព្យសម្បត្តិរដ្ឋ<br>២. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ<br>៣. ប្រព័ន្ធគ្រប់គ្រងស្ថិតិបុគ្គលិក(កម្រងប្រវត្តិរូបបុគ្គលិក)<br>៤. ប្រព័ន្ធគ្រប់គ្រងស្ថិតិគរុសិស្ស គរុនិស្សិត (កម្រងប្រវត្តិរូបគរុសិស្ស គរុនិស្សិត)<br>៥. ប្រព័ន្ធគ្រប់គ្រងការបង្រៀននិងរៀន | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| ៤.១.៤ | ការវាយតម្លៃការបំពេញការងារបុគ្គលិក | ១. ប្រព័ន្ធវាយតម្លៃបុគ្គលិកផ្អែកលើលទ្ធផល<br>២. កិច្ចព្រមព្រៀងការបំពេញការងារប្រចាំឆ្នាំ<br>៣. ការវាយតម្លៃបុគ្គលិកដោយផ្អែកលើលទ្ធផល<br>៤. ការសិក្សាពីលទ្ធផលនៃការវាយតម្លៃដើម្បីផ្តល់ការលើកទឹកចិត្តនិងកែលម្អ<br>៥. ប្រព័ន្ធលើកទឹកចិត្ត | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| **៤.២. ការធានាគុណភាពគ្រឹះស្ថាន** | | | | | | | |
| ៤.២.១ | ការធានាគុណភាពផ្ទៃក្នុង | ១. ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង<br>២. គណៈកម្មការវាយតម្លៃផ្ទៃក្នុង<br>៣. វដ្តនៃការវាយតម្លៃច្បាស់លាស់៖ ការរៀបចំផែនការ (Plan) ការអនុវត្តការវាយតម្លៃ (Do) ការវាយតម្លៃនិងវាស់វែងលទ្ធផល (Check) និងការកំណត់ចំណុចដែលត្រូវកែលម្អ (Action)<br>៤. ឧបករណ៍វាយតម្លៃលើគ្រប់ផ្នែក<br>៥. ការរៀបចំស្វ័យវាយតម្លៃតាមដេប៉ាតឺម៉ង់/ការិយាល័យ<br>៦. ការពិនិត្យតាមដាន និងវាយតម្លៃ (កាលវិភាគនៃការវាយតម្លៃ ការប្រមូលរបាយការណ៍និងទិន្នន័យ និងធ្វើការវិភាគ)<br>៧. ការរៀបចំរបាយការណ៍<br>៨. ការផ្សព្វផ្សាយរបាយការណ៍ជាមួយអ្នកពាក់ព័ន្ធ<br>៩. ការរៀបចំឯកសារពាក់ព័ន្ធសម្រាប់ការវាយតម្លៃផ្ទៃក្រៅ | មាន៥ចំណុច | មាន៦ចំណុច | មាន៧ចំណុច | មាន៨ចំណុច | មាន៩ចំណុច |
| ៤.២.២ | ការធានាគុណភាពផ្ទៃក្រៅ | ១. គណៈកម្មការវាយតម្លៃអប់រំ<br>២. ស្វ័យវាយតម្លៃ និងរបាយការណ៍វាយតម្លៃ<br>៣. ការដាក់ពាក្យសុំការវាយតម្លៃពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គទក)<br>៤. ការចុះវាយតម្លៃដល់គ្រឹះស្ថានដោយ គទក<br>៥. ការទទួលស្គាល់គុណភាពអប់រំ (បណ្ដោះអាសន្នឬពេញសិទ្ធិ) | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| **៤.៣. ការពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីបណ្ដុះបណ្ដាល** | | | | | | | |
| ៤.៣.១ | ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីបណ្ដុះបណ្ដាល | ១. យន្តការពិនិត្យ តាមដាន និងវាយតម្លៃ<br>២. ផែនការពិនិត្យ តាមដាន និងវាយតម្លៃ<br>៣. ការអនុវត្តការពិនិត្យ តាមដាន និងវាយតម្លៃ | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |

| ល.រ | សូចនាករ | ចំណុចត្រូវផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| | | ៤. របាយការណ៍ពិនិត្យតាមដាន វាយតម្លៃ<br>៥. ការផ្សព្វផ្សាយលទ្ធផលពិនិត្យតាមដាន វាយតម្លៃជាមួយអ្នកពាក់ព័ន្ធ | | | | | |
| **ស្តង់ដាទី៥ ៖ ការស្រាវជ្រាវ និងនវានុវត្តន៍** | | | | | | | |
| **៥.១. ការលើកកម្ពស់ការងារស្រាវជ្រាវ និងនវានុវត្តន៍** | | | | | | | |
| ៥.១.១ | ការស្រាវជ្រាវប្រតិបត្តិ | ១. សៀវភៅណែនាំការស្រាវជ្រាវប្រតិបត្តិ<br>២. គណៈកម្មការគាំទ្រ ពិនិត្យ ណែនាំ និងកែលម្អការងារស្រាវជ្រាវ និងការបោះពុម្ព<br>៣. គ្រូឧទ្ទេសយ៉ាងតិច៥០% អាចដឹកនាំ គរុសិស្ស គរុនិស្សិតធ្វើគម្រោងស្រាវជ្រាវប្រតិបត្តិ<br>៤. គ្រូឧទ្ទេសយ៉ាងតិច៥០% ធ្វើការស្រាវជ្រាវប្រតិបត្តិ<br>៥. ការបង្កើតកិច្ចសហការគម្រោងស្រាវជ្រាវរួមគ្នាជាមួយគ្រឹះស្ថានអប់រំនានា | មាន១ចំណុច | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច |
| ៥.១.២ | ការបោះពុម្ព និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ | ១. ព្រឹត្តិបត្រស្រាវជ្រាវផ្ទៃក្នុងត្រូវបានបោះពុម្ពផ្សាយប្រចាំឆមាស ឬប្រចាំឆ្នាំ<br>២. ការរៀបចំសន្និសីទស្រាវជ្រាវប្រចាំឆ្នាំ ដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវក្នុងចំណោមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន<br>៣. ការចូលរួមធ្វើបទបង្ហាញក្នុងវេទិកានិងសន្និសីទ ស្រាវជ្រាវ នានា<br>៤. ការបោះពុម្ពលទ្ធផលស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវក្នុងឬក្រៅប្រទេសយ៉ាងតិច២<br>៥. របាយការណ៍ស្រាវជ្រាវប្រតិបត្តិរបស់គរុសិស្ស គរុនិស្សិតយ៉ាងតិច២ ត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ឆ្នាំ<br>៦. របាយការណ៍ស្រាវជ្រាវប្រតិបត្តិរបស់គ្រូឧទ្ទេសយ៉ាងតិច៥ ត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ឆ្នាំ | មាន២ចំណុច | មាន៣ចំណុច | មាន៤ចំណុច | មាន៥ចំណុច | មាន៦ចំណុច |

| ល.រ | សូចនាករ | ចំណុចត្រួតផ្ទៀងផ្ទាត់សូចនាករ | កម្រិតផ្ទៀតផ្ទាត់លទ្ធផល | | | | |
|---|---|---|---|---|---|---|---|
| | | | ពិន្ទុ ១ | ពិន្ទុ ២ | ពិន្ទុ៣ | ពិន្ទុ៤ | ពិន្ទុ៥ |
| ៥.២. ការកសាងឯកសារ/សៀវភៅមេរៀន | | | | | | | |
| ៥.២.១ | ការនិពន្ធចងក្រងសៀវភៅមេរៀន | ចំនួនសៀវភៅមេរៀនសម្រាប់បង្រៀនដែលបាននិពន្ធចងក្រងក្នុងចំណោមគ្រូឧទ្ទេសទៅតាមមុខវិជ្ជានីមួយៗស្របតាមកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ | ២-៥ | ៦-១០ | ១១-១៩ | ១៩-២០ | ≥ ២១ |
| ៥.២.២ | ការបោះពុម្ពសៀវភៅមេរៀន | ចំនួនសៀវភៅដែលបានបោះពុម្ពសម្រាប់ទុកក្នុងបណ្ណាល័យនិងប្រើប្រាស់សម្រាប់បង្រៀន និងរៀនប្រចាំឆ្នាំ | ៥០-៥៩ | ៦០-៦៩ | ៧០-៧៩ | ៨០-៨៩ | ≥ ៩០ |

# តារាងពិន្ទុសរុបវាយតម្លៃសាលាគរុកោសល្យគំរូ

| ស្តង់ដា | ស្តង់ដាទី១ | ស្តង់ដាទី២ | ស្តង់ដាទី៣ | ស្តង់ដាទី៤ | ស្តង់ដាទី៥ | សរុប |
|---|---|---|---|---|---|---|
| | លទ្ធផលបណ្តុះបណ្តាល | ធនធានបណ្តុះបណ្តាល | កិច្ចសហប្រតិបត្តិការ | អភិបាលកិច្ចល្អ | ការស្រាវជ្រាវ និងនវានុវត្តន៍ | |
| ចំនួនស្តង់ដារង | ០២ | ០៤ | ០២ | ០៣ | ០២ | ១៣ |
| ចំនួនសូចនាករ | ១១ | ២០ | ៩ | ៧ | ៤ | ៥១ |
| ពិន្ទុអតិប្បរមា | ៥៥ | ១០០ | ៤៥ | ៣៥ | ២០ | ២៥៥ |
| ពិន្ទុជាប់ស្តង់ដា (៦០%) | ៣៣ | ៦០ | ២៧ | ២១ | ១២ | ១៥៣ |